# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ

អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ

ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះទេពសត្ថា សួរ-ហាយ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ឃុនសិរីមេធី ស្រី-អ៊ួ | បណ្ដាំមាតា | ៨១១ |
| ភិក្ខុ ឈឹម-សារេត | របរធ្វើស្រែ | ៨០៦ |
| លោក ភិយ-ប៊ុក ក្រមការ | សុភាសិតខ្មែរកាតទី ២ (តមក) | ៨២១ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ស័ព្ទបារាំងប្រែជាខ្មែររបស់គណៈកម្មការវប្បធម៌ (តមក) | ៨២៨ |
| — | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តមក) | ៨៣៩ |
| អ្នកនកញ៉ាព្រះឃ្លាំងឯង | រឿងភោគកុលកុមារ ពាក្យកាព្យ (តមក) | ៨៤៩ |
| **ផ្នែកសាសនា** | | |
| លោក ភិយ-ប៊ុក ក្រមការ | ពុទ្ធអាស៊ីទ្វីប (តមក) | ៨៥៥ |
| មហា ខឹម-ណាគ្រី | និរយកថា (តមក-ចប់) | ៨៦៦ |
| **កំណត់ហេតុប្រវត្តិការណ៍** | | |
| ក្រសួងធម្មការ | បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) | ៨៧២ |
| លោក ភិយ-ប៊ុក ក្រមការ | កំណត់ស្ដើអំពីរឿងស្ថាបនាវិទ្យាស្ថានមួយសម្រាប់សិក្សាភាសាខ្មែរ ឥណ្ឌា នៅភ្នំពេញ | ៨៧៨ |

ឆ្នាំទី ២១ — លេខ ១១ ខែវិច្ឆិកា ឆ្នាំ ១៩៤៩ — ថ្លៃជាវ ១ ឆ្នាំ ៩៦ រៀល

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî

NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable

Brah Déb Sattha SO-HAY membre de la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire :**


| | | page |
|---|---|---|
| Khun-Sirimedhi Sry-Ou | Conseil de la mère .................... | 801 |
| Phikhu Chhim-Sareth | Les Travaux des rizières.... ....... | 806 |
| M. Ray-Buc Kramakar (I.B.) | Proverbes et maximes Tome II (suite) | 821 |
| Luong Nibandhamantrî NHOK-THÈM | Recueil des mots traduits par la Commission des mœurs et coutumes (suite) | 825 |
| —id— | Histoire sommaire de l'Inde (suite) .. | 839 |
| Néak Oknha Nong | Bhugkul kumar poésie (suite) ..... | 845 |


**Partie religieuse:**


| | | |
|---|---|---|
| M. Ray-Buc kramakar (I.B.) | La Lumière d'Asie (suite) ........ | 855 |
| Mahâ OM-NAGRY. | Nirayakathâ (suite et fin)........... | 864 |


**Notes et chroniques**


| | | |
|---|---|---|
| Ministère des cultes | Nomination des nouveaux chau Adhikar (suite) .................... | 872 |
| M. Ray-Buc Kramakar I. B. | Note proposant la création d'un centre de hautes études Indo-Khmères à P.-Penh (Traduction).... ...... ... | 878 |


21e Année: No 11 Novembre 1949 — Prix d'abonnement: 96$00 par an.

# បណ្ដាំមាតា

យុន សារមេធី ស្រី-អ៊ូ ក្រុមជំនុំព្រះត្រៃបិដកក្រសួងពុទ្ធសាសនបណ្ឌិត្យជាអ្នករៀបរៀង ដោយបានឃើញច្បាប់ចាស់ ក្នុងក្រាំងមួយឈ្មោះច្បាប់ស្រីកាព្យពាក្យ ៧ មានសេចក្ដីពីរោះសមរម្យគួរយកមកចុះផ្សាយក្នុងសៀវភៅកម្ពុជសុរិយានេះ តែច្បាប់នោះលុបបាត់ខ្លះ ឃ្លាល្បះកាព្យឃ្លោងក៏មិនសូវត្រឹមត្រូវតាមច្បាប់កាព្យផង ទាំងមិនឃើញឈ្មោះអ្នកតែងនោះទៀតផង ៗ ខ្ញុំក៏តែងបន្ថែមបំពេញសេចក្ដី កែតម្រង់ឲ្យបានត្រឹមត្រូវតាមច្បាប់កាព្យទាំងប្រែឈ្មោះដើមចេញ ឲ្យឈ្មោះបាបណ្ដាំមាតាវិញ ព្រោះឃើញសេចក្ដី ក្នុងផ្ទៃច្បាប់នោះ ជាទុកាទមាតាទូន្មានកូនស្រី ៗ

## កាព្យ ពាក្យ ៧

| | |
|---|---|
| រឿងនេះខ្ញុំឯងតែងចងលើក | ជាកាព្យល្បិចល្បើកពាក្យនេះណា |
| សម្រិទ្ធិសម្រាំងដោយសញ្ញា | ទុកជាទំនងតរៀងទៅ ៗ |
| ជាច្បាប់មាតាទុកទូន្មាន | កូនស្រីគ្រប់ប្រាណដែលល្ងង់ខ្លៅ |
| ពុំដឹងកិច្ចកលការពក់ព្រៅ | ប្រដៅឲ្យដឹងក្ដីគួរសម ៗ |
| តែងតាមពាក្យចាស់លោកលើកមក | គ្រាន់តែលៃលកកែបន្សំ |
| គ្រប់ពាក្យ ៧ តាមនិយម | បញ្ចូលពាក្យផ្សំតាមបរិយាយ ៗ |

ទឹងថែងបរចាចាហៃស្ងួន    ពន្ធកខឹមខ្លួនសំឡាញ់ម្តាយ
ចូរនាងស្ដែងស្ដាប់អក់ប្រាយ    តោមឆាយកុំនាងគិតផ្ដេសផ្ដាស ។
ដ្បិតនាងនេះជំក្រមុំពិត    កុំពុងចូលចិត្តកញ្ចក់ក្រាស
ក្រមួនប្រេងម្សៅខ្មៅចារុំមាស    ចំពៀនកងពាសពាក់ដើងដៃ ។
ខ្លួននាងក្រមុំត្រូវគិតក្រែង    កុំស្រែបដោយល្បែងទោះយប់ថ្ងៃ
កុំដើរមើលល្ខោនមើលអាយៃ    ចាំថ្ងៃដល់ខ្លួនស្ងួនពុំងា ។
កុំលោតអន្ទាក់លាក់កន្សែង    រត់ចាប់កូនក្ងែងបញ្ចូលទា
ឈរមើលយ៉ីកេបែរបៀតគ្នា    ពុំងាយ៉ាងនេះប្រុសមើលងាយ ។
កុំលេងបៀហ៊ោធ្នូស៊ីសង    លេងនោះខុសក្តងណាស់ស្ងួនម្តាយ
ជក់អាភៀនផឹកស្រាផងទាំងឡាយ    ខូចកាយកុំធ្វើអំពើហ្នោះ ។
រាំរោតឯល្បែងផងស្រញ៉ី    កុំទៅរករៃក្សឲ្យសោះ
នាំឲ្យបោកចយអាប់កេរ្តិ៍ឈ្មោះ    គឺមោះពុំត្រូវនឹងច្បាប់ស្រី ។
ធម្មតាកំឡោះនឹងក្រមុំ    កុំលេងលាយឡំនៅដោយដី
ពុំដែលត្រង់ទេមេកុំបី    ជឿចិត្តប្រុសនោះណា៎នាង ។
ខ្លួននាងក្រមុំសមពាងរូប    កាយកូនក្រអូបសព្វសពាង្គ
ប្រុសព្រើលនឹងវប់ឈប់កសាង    ឃើញនាងញញឹមញាក់រកគ្នា ។
ហើយចូលមកលេងនឹងឯងគត    មានកោតក្រែងចិត្តក្រែងចិន្ដា
លូកឡកឡុមឡុំសុំដល់ស្មា    ហាក្មាអង្អែលខបអង្គឯង ។

ព្រោះគេឃើញខ្លួនខ្លួនពិសី ដើរលេងដោយដឹកគងនៃក្រង
ទំនើងតែចិត្តបង់ប្រឡែង បំបែងនឹងអ្វីស្រីស្រើបស្រាល ៗ
ម្ល៉េះហើយនឹងកើតក្តើអាស្រូវ កាចខ្នាសគេកូវក្ដងាលព៉ាល
គេដឹងសព្វស្រុសប្រុសពេញពាល កុំស្គាល់ស្នេហ៍ស្និទ្ធជិតមេត្រី ៗ
ខាងនៅខកសល់ដល់សោរកៃ គ្មានប្រុសមួយស្នេហ៍ស្និទ្ធប៉ែតី
ឃ្សិតលេងពាក្យពេចន៍ពុំគប្បី ព្រល្បីជាក់ជាអ្នកលេងរេប ៗ
ហេតុនោះឯងមិញសំឡាញ់ម្តាយ កុំគិតសប្បាយហើយបំភ្លេច
អស់ច្បាប់ទម្លាប់សព្វសេចក្រែប រះគេចដើរលេងមិនខុសព្រាហ៍ ៗ
ជាស្រីកុំលេងល្បែងទាំងអស់ នឹងខូចកេរ្តិ៍យសខុសលក្ខណា
ខុបទ្រពចង្រែងក្រែមហិមា ទុក្ខាដល់ប្រាណមានប្រាកដ ៗ
ខ្លួនកើតជាស្រីស្រេបម្ការ រៀនធ្វើការងារឲ្យមានបទ
រៀនត្បាញរវៃឲ្យម៉ត់ចត់ កុំគិតទៀយហាត់ខំឲ្យមួន ៗ
រៀនដេរខោអាវខ្នុរខ្នើយខ្នល់ ពុកកែបកើយកល់ជាទ្រព្យខ្លួន
គ្រឿងប៉ាក់ស្រះស្រាក់ជាក្បាច់ក្បួន ជួសជុលបូរសួនរៀនឲ្យគ្រប់ ៗ
ចង់គោមគាតកៃប្រែឲ្យស្រេច រំលើករំលេចឲ្យស្រុសសព្វ
ចង់ជាផ្កាពុលផ្កាយ៉ើហ៊ិប ជរជាប់ជាយស៊ិបគួរយង់យល់ ៗ
ចង់ជាបុប្ផាផ្កាទទឹម តម្រង់តម្រឹមឲ្យអស់កល់
ក្នក់ពេជ្ររំលេចដោយយោបល់ កុំឲ្យមានសល់សោះជាម្តង ៗ

រៀនបង់ដាហង្សពង់ពេនពើត ដំទាញដំទើតទំផ្អៀងផ្អង
ហាំបហោះផ្ទុះផ្ទោះរកផលផង ហើយបង់ដារូបសត្វបក្សី ៗ
បង់ដាបាបតូកបាបដង្កូវ ប្តូចាប់សុីស្រូវណាកូនស្រី
បង់ដារូបដៀបកប្បាសទ្វី ពីសើបង់ដាផ្កាក្រចាប់ ៗ
រឿងខាងឯហូលរៀនឲ្យចេះ ឲ្យស្ទាត់រឿងនេះហ័សផាប់
បង់រូបផ្ទលក់គក់ប្រញាប់ ផ្គូផ្គាប់ត្បាញទៅពៅពុំងា ៗ
ឯព្រៃរៀនកែគិតវៃលើក ជាត់ជាល្បិចល្បីកតាមប្រាជ្ញា
កុំឲ្យមានទាល់សល់ត្រង់ណា ឧស្សាហ៍សន្សំកុំធ្លោយ ៗ
សង្កាត់ខ្ទីឃ្មាតឲ្យម៉ាំមួន ធ្វើហើយចែងដួនមើលមុខក្រោយ
ក្រែងក្តែប្រចាំនាំដាប់ដោយ ប្រយ័ត្នកុំឲ្យពិបាកម្តាយ ៗ
ធ្វើការដៃទោះថ្ងៃយប់ សំងំស្ងៀមស្ងប់កុំនិយាយ
ពាំនេះពាំនោះស៊ុសសព្វសាយ ហើយសើចក្អាកក្អាយពៅពីសី ៗ
មួយទៀតខំឆ្ងៀតរៀនអក្សរ រៀនធម៌រៀនអាប៌រៀនសំដី
រៀនសព្វស៊េចក្រែបពាក្យពេចន៍ក្តី លោកិយនេះទើបប្រឡៃគេ ៗ
មួយខ្ទួនក្រមុំកុំធ្វើការ អន្ទុយមាត់ទ្វារណាមាសមេ
ទោះយប់ទោះថ្ងៃចរៃទេ ពុំនោះសោតទេខាតលក្ខណា ៗ
កុំធ្វើបុកពារបែបឡេះឡោះ ប្រុសពាសពេញនោះហើយយាត្រា
បង់បោយក្រែវែងក្រែលែងស្នា ចរចាញញឹមធ្វើសំដី ៗ

ចំអន់ចំអកឡកនេះនុះ    មិនទាញមិនតុះផ្ដើប្រិមប្រិយ
សំឡឹងសំឡក់ដូចឃើញអ្វី    ស្រងៃរែកចំគ្នានទីងទួន ។
ខាងផ្ទើយានីនេះគេរិះគិត    ទុកជាបោរចិត្តទៅហើយសួន
គេទីងប្រមាទដាបដល់ខ្លួន    គេកូនរៃងកើតការស្រវ៉ៃក្រ ។
កុំសើយកុំលាត់ព័ទ្ធពាតបុ    កុំចរយាត្រាចូលព្រៃផ្សៃ
ពាក់អាវគ្រប់ខ្លួនកុំនមាសថ្លៃ    កុំដើរស៊យស្រីអ្នកលេង ។
ផ្ដើបុកសង្ហាត់តខ្លាសរសោះ    ស្លៀកពាក់ឃើញពោះអស់កើ្តងេង
បុកពាមារយាទដូចកូនក្មេង    ពេលគេនីលៃងដោះអស់បេញក្រោយ
ស្រីនោះពិតពុំប្រពៃទេ    មាសមេកុំបៀតណាពាលទៅ
កុំតាមកុំត្រាប់រាប់ជាធៅ    ពុំបោត្រូវច្បាប់ទេណាខាង ។
កង់លោកសព្វថ្ងៃស្រីកង់ក្រៅ    បៃរមៀងមើលទៅសព្វសព្ទា
គតលក្ខណ៍កង់ប្រាណមានតែរាង    បើខាងផ្ដើខ្លួនទុកផារបុះ ។
មួយថ្ងៃផ្ដើខ្លួនប្អូនដប់ដង    កាច់កកាច់ស្រង្គសើចហ៊ះហុះ
ផាត់ម្សៅសិតសក់កញ្ចក់ឆ្ពុះ    រៀវរឹងរឹតសិតបន្ទេ ។
លាបព្រែងក្រមួនជូនថែមទៀត    ផាត់ម្សៅរមៀតមើលតតល្ហៃ
កន្ទ្រាក់កញ្ចក់ស្ទុះស្ទើរតែ    រលំផ្ទះគ្រែផ្ចុកស្គ្រី ។
មកឆ្ពុះសព្វស្ទុសដប់ដងគត់    ចាប់យកសំពត់ស្លៀកសក្តិសម
ពាក់អាវថ្ងោងថ្មីដែលមានចំ    បន្ទំចរចុះឲ្យប្រុសមើល ។ (មានត)

របរធ្វើស្រែ

១ អំពីការធ្វើស្រូវប្រាំង, ២ ស្រូវស្ទូង, ៣ ស្រូវពង្រោះ,

របស់ភិក្ខុ ឈិម - សារេត

សិស្សសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

---

## ស្រូវប្រាំង

ស្រូវប្រាំងនេះ គេធ្វើឥតពឹងដល់ទឹកភ្លៀងទេ តែត្រូវអាស្រ័យ-នឹងទឹកព្រែកបុឹង ហើយធ្វើតែក្នុងរដូវអស់ទឹកភ្លៀង គឺក្នុងគិម្ហរដូវ បានជាឈ្មោះថា " ស្រូវប្រាំង " ។

**របៀបធ្វើ** ក្នុងរវាងរនោចខែបុស្សឬខ្នើតខែមាឃ ត្រូវរកកន្លែងសាបសំណាប ឯថ្នាលសាបនោះ ត្រូវធ្វើក្បែរមាត់ព្រែកឬមាត់បឹង ដើម្បីនឹងបាចទឹកពីព្រែក - បឹងដាក់ ។

**អំពីពូជ** ស្រូវសម្រាប់ធ្វើស្រែប្រាំង គេជ្រើសយកតែស្រូវបែព-ម្យ៉ាង ព្រោះស្រូវនេះស្រាល * រវាង ៣ ខែប៉ុណ្ណោះទុំបានបែក ។

**កន្លែងធ្វើ** របៀបធ្វើដែលពោលមកនេះ នៅក្នុងខែត្រស្វាយរៀង គេធ្វើតែក្នុងផ្ទៃបឹងនឹងផ្ទៃព្រែក ព្រោះនៅផ្ទៃបឹងនេសាទនឹងផ្ទៃព្រែកស្វាយរៀង វេលាខែប្រាំងទឹកនៅតិចល្មមធ្វើស្រូវបាន ។

វិធីដែលទី៣ធ្វើនោះទៀត ឥតមានលំបាកនឹងក្លួរការសំអុះឡើយ ព្រោះក្នុងផ្លូវព្រែកនោះ មានភក់ល្បាប់ជីទន់ស្រាប់ គ្រាន់តែដកសំណាបទៅស្ទូងប៉ុណ្ណោះ ស្ទូងទឹកក៏មិនបាច់យាងបុបាចដាក់ដែរ ព្រោះព្រែកនោះមានទឹកជោរនាច វេលាទឹកជោរឡើងក៏រាបទៅសព្វគុម្ពស្ទូង ដល់ទឹកនាចទៅវិញពេញ ១ សប្ដាហ៍ប៉ុណ្ណោះនឹងជោរឡើងវិញ ដូច្នោះសើមជាប់ជានិច្ច ឥតមានស្ងួតស្ងួនឡើយ ។ ប៉ុន្តែអ្នកដែលធ្វើស្រែ ក្នុងផ្លូវបឹងនេះសារ ទៀយហាត់បន្តិច ព្រោះបឹងនោះមានដៃទៅជាប់នឹងព្រែក វេលាទឹកឡើងច្រើនក្នុងផ្លូវបឹងក៏មានទឹកច្រើន បើទឹកនាចផ្លូវបឹងក៏មានទឹកនាចដោយអន្ទើ ព្រោះហេតុនោះ អ្នកធ្វើស្រែក្នុងបឹង ត្រូវធ្វើទំនប់ ១ ត្រង់ដៃបឹងសម្រាប់បើកឲ្យទឹកចូល ក្នុងពេលទឹកជោរ សម្រាប់ទប់ទឹកទុកក្នុងពេលដែលនាច ហើយក្នុងផ្លូវបឹងនោះមានស្មៅច្រើន ត្រូវបោចស្មៅរួចសិមស្ទូង ។ អ្នកស្ទូងត្រូវស្ទូងឲ្យរង្វើល ៗ ចំនួន ៥០ សង្ទីម៉ែត្រពីគ្នា ព្រោះផ្លូវព្រែក - បឹង តែងល្អជាងស្រែធម្មតា វេលាដែលស្ទូងរួចហើយ ត្រូវចាំថែមើលកុំឲ្យគោក្របីស៊ី ព្រោះរដូវនេះប្រាំងអ្នកស្រុកលែងគោក្របីឥតបើគិត ។

**វិធីបួងសួង** វេលាដែលស្ទូងរួចរាល់សព្វគ្រប់ហើយត្រូវធ្វើរបៀបសម្បូងសម្រង់ ដល់ម្រេញគង្វាលដែលនៅរក្សា ដង - ស្ទឹង - បឹង - ព្រែក ត្រូវធ្វើបាយ៉ាប ហើយដាក់នំបំណី ពូតបាយ ៤ ពំនូតដាក់លើបាយ៉ាប

រួចយកទៅដោតនៅមាត់ព្រែកឬបឹង ឬក៏ត្រង់កន្លែងណាដ៏សមគួរ ហើយអំពាវថា ហ៎ អស់លោកនៅរក្សាទឹកដីនេះ ខ្ញុំសូមថ្វាយចុយ៉ាបនេះ ហើយសូមឲ្យលោកជួយរក្សាដំណាំ ថែមទាំងកុំចាប់ទោសអ្វីដំណើរដល់ខ្ញុំដែលមកនៅលើទឹកដីនេះ ។

ឯរបៀបធ្វើចុយ៉ាបនេះ សូមមើលក្នុងរឿងធ្វើស្រូវតាព្រោះធនិងចុះ

វេលាដែលសន្ទូងបែកគុម្ព បើនៅមានដីទូលាយមិនទាន់ស្ទូង អាចនឹងបំបែកពីគុម្ពដែលរីកធំៗ ទៅស្ទូងទៀតបាន ដល់វេលាចេញផ្កាក៏ចេញដំណាលគ្នា ។

លុះពេលដល់ស្រូវទុំល្មមច្រូតហើយ ក៏ចាប់ច្រូតដូចស្រូវវស្សាដែរ តែគ្មានវិធីក្ដេកដោយឈើក្ដេកទេ ។ ទាំងរបៀបយកគ្រាប់ស្រូវ ទឹងយកស្រូវងាក់ចង្អិក ក៏ដូចគ្នាក្នុងរឿងធ្វើស្រូវវស្សានោះដែរ ។

រឿងធ្វើស្រូវប្រាំងនេះ មិនសូវមានរបៀបរៀបរយប៉ុន្មានទេ ទាំងរឿងព្រេងសោតទៀតក៏គ្មាន ប៉ុន្តែបានជាប្រឹងបរិយាយរឿងនេះ ដោយយល់ឃើញថា "របរស្រូវប្រាំង" នេះ ជារបរមានប្រយោជន៍ធំមួយក្នុងសរទកាល ក្នុងកម្ពុជរដ្ឋនេះ ។

## រឿងធ្វើស្រូវស្ទូង

របរធ្វើស្រែនេះ ជារបរមានប្រយោជន៍យ៉ាងធំបំផុតនៅស្រុកខ្មែរ ហើយជារបរសំខាន់ក្នុងការចិញ្ចឹមជីវិត នៃជនក្នុងទ្វីបអាស៊ីទាំងមូល មិន

តែប៉ុណ្ណោះ របរធ្វើស្រែនេះមានជាប់មកយូរយារណាស់ហើយ មាននិយាយក្នុងគម្ពីរធម្មបទគាថាទី ១ ពីទំព័រ ៦៤ ដល់ ៧៦ មានសេចក្ដីដំណាលថា កាលព្រះសម្ពុទ្ធទ្រង់បានត្រាស់ថ្មីៗ ទ្រង់សំដែងធម្មទេសនា ប្រារព្ធអំពីការចងពៀរ លុះចប់ហើយមានយក្សស្រីម្នាក់បានសំរេចធម៌ជាន់ខ្ពស់ ព្រះសម្ពុទ្ធទ្រង់ប្រគល់នាងយក្សនោះឲ្យទៅស្រីម្នាក់ជាសំឡាញ់នឹងគ្នាពីពេលមុនឲ្យថែរក្សាចិញ្ចឹមបាយទឹក ។ ថ្ងៃងពីអ្នកស្រុកទាំងនោះធ្វើស្រែមិនបានផលសោះ បូនរាំងគ្មានទឹក ទឹកស្ងួតរលួយទៅក៏មាន ។ កាលគ្រានោះនាងយក្ខនីឃើញឧបការគុណ របស់ស្រីជាសំឡាញ់នោះទើបនិយាយប្រាប់ថា ឆ្នាំនេះភ្លៀងស្រួលនាងធ្វើតែស្រែណាទួល ។ ហើយបើឆ្នាំណាភ្លៀងមិនស្រួលក៏ប្រាប់ថា ឆ្នាំនេះភ្លៀងមិនស្រួលទេ ចូរនាងធ្វើតែស្រែណាទំនាបៗហើយ ព្រោះនាងយក្ខឈ្លាសក្នុងវិជ្ជាដឹងទឹកភ្លៀងៗ អ្នកនគរបានដំណឹងនេះ ក៏នាំគ្នាយកនំចំណីត្រសាប់ទៅជូននាងយក្ខ ហើយសួរអំពីទឹកភ្លៀង នាងយក្ខក៏ប្រាប់តាមទំនងនោះ អ្នកនគរធ្វើស្រែបានផលរៀងរាល់ឆ្នាំតមក ។

ប្រហែលជាទំនងនេះហើយ បានជាអ្នកស្រែមានវិធីសែនជាប់តហូរហូរមកដល់សព្វថ្ងៃនេះ ។

## គ្រឿងប្រដាប់ធ្វើស្រែ

ប្រដាប់ធ្វើស្រែស្លូវត្រូវមាន នង្គ័ល, រនាស់, នឹម, ខ្សែទាម, ពួរ, ខ្សែព្រាត់, កន្ទះ, ចបកាប់ ។ នង្គ័លជារបស់សម្រាប់ភ្ជួរស្រែ មានយាម,

ដង, ក្អៀង, យាមគេច្រើនយកមែកឈើ ឬ ឫសឈើ ដែលមានសណ្ឋាន កោងដូចដងអន្ទាក់ យកមកចាំងប្រាសធ្វើឲ្យស្រួល ខាងគល់ធំ តូចទៅៗ ទៅខាងចុងមូល ដើម្បីស្រួលកាន់, បើចង់ឲ្យល្អ គេយកស្ពាន់ក្រហមមកចងជាចង្កឹះទៀត ។ ដង: ដងនង្គ័លប្រវែងជាង ៣ ម៉ែត្រ ខាងគល់សំប៉ែត ទំហំបន្ទា ១៣ - ១៤ សង្ទីម៉ែត្រ, ទោលទំហំ ៣ - ៤ សង្ទីម៉ែត្រ តូចទៅៗ ទៅខាងចុងហើយងើងឡើងបន្តិច ។ ក្អៀង: នេះគេធ្វើសម្រិតសម្រាំងណាស់ធ្វើតែក្អៀង ១ អាចប្រើបាន ៣ - ៤ ឆ្នាំ គេរើសរកឈើមានសាច់ជាប់យូរមានដើមធ្ងន់ជាដើម ហើយរកតែចំពាមដែលគ្រាន់តែចាំងប្រាសសម្រួលបានគាពជាក្អៀង វេលាចាំងប្រាសរួចហើយគេយកដែកអង្រែសរុសឲ្យរលីង រួចយកអាចម៍ល័ខគាល ហើយយកអំបែងឆ្នាំងខ្ទះបុកក្លាប់នឹងអាចម៍ល័ខ ដើម្បីកុំឲ្យសឹកសាច់ឈើហើយបញ្ចូលផ្លែដែកឬផាលដែកខាងមុខ ដើម្បីឲ្យមុតដីបានស្រួល ។ រួម យាម, ដង, ក្អៀង ចូលគ្នាហៅថា នង្គ័ល ។ នោស: នោសមានដង, មេ, នឹងធ្មេញ; ដងនោសប្រហែលនឹងដងនង្គ័លដែរ ។ មេនោសគេយកឈើប្រវែងពីរម៉ែត្រ បន្ទារប្រហែល ១៥សង្ទីម៉ែត្រ ទោល ៦ សង្ទីម៉ែត្រ ឈូសឲ្យរៀវចុងទាំងសងខាងបន្តិច ។ រួចចោះរន្ធចម្ងាយ ១៥ សង្ទីម៉ែត្រពីគ្នាសម្រាប់បញ្ចូលធ្មេញ ធ្មេញ: ធ្មេញនោសយកឈើខ្លឹមតូចៗ មូលស្រួចសម្រាប់ដាក់បញ្ចូលទៅក្នុងមេ; រួមដង, មេ, ធ្មេញចូលគ្នាហៅថានោស ជារបស់

សម្រាប់ពាស់ដីឲ្យរាប និងចូលស្មៅដែលទាប់ឲ្យជាប់នឹងធ្មេញរនាស់យកទៅចោលផង ៗ ត្បូរ: របស់ដែលធ្វើពីធាងត្នោត ឬ ធាងទ្រាំង គេយកធាងទាំងនោះទៅដំឲ្យទន់រួចក្ដញវេញជាបីផ្នង សម្រាប់ចងទាក់ផងទន្ទ្រឹលនោស់ៗ ត្រូវខ្វែងឲ្យជាពកបន្តិច ដើម្បីទប់ត្បូរកុំឲ្យរអិលចុះឡើង) ៗ ខ្សែរបស់សម្រាប់ចាប់, ចង ដឹកសត្វពាហនៈ (ក្របីគោ) គេយកស្រទបត្នោតមកដំឲ្យល្អិត រួចដុះកំទេចឲ្យអស់នោសល់តែជក់វែង ៗ ទើបគេផ្ញបញ្ចូលគ្នាឲ្យមានទំហំតូចល្មម ហើយក្ដញឲ្យខ្វាញ់វេញបញ្ចូលគ្នាជាបីផ្នង ប្រវែង ២ ម៉ែត្រ ៗ កន្ទុះសម្រាប់ចាប់គោក្របីក្ស បើធ្វើខ្សែបំណង គឺខ្សែសម្រាប់ចងបណ្ដោយឲ្យរាសុីស្មៅ ត្រូវវេញប្រវែង ៩ - ១០ ម៉ែត្រ ៗ ខ្សែទាមគឺខ្សែចងជាប់នឹងនឹមទាញមកក្រោមកក្របីគោ ហើយចងភ្ជាប់នឹងចុងនឹម ៗ នឹម= ឈើមានសណ្ឋានមូលប្រវែង ៤ ហត្ថសម្រាប់ដាក់លើកក្របី ហៅថានឹម ៗ កន្ទុះ= គឺខ្សែដែលដោតទៅក្នុងច្រមុះក្របីគោ គេធ្វើពីជក់ត្នោត ឬ ធាងត្នោតដែរ តែធ្វើហ្មត់ចត់តូចជាងហើយខ្លីប្រហែល ៤ ហត្ថប៉ុណ្ណោះ ៗ

**ឈ្មោះស្រូវ** ស្រូវមានឈ្មោះច្រើនយ៉ាង គឺស្រូវប្រពៃ ១ ស្រូវអង្គសារ ១ ស្រូវខ្វែង ១ ស្រូវអង្គស្និទ្ធ ១ ស្រូវកូនត្រី ១ ស្រូវអំម៉ុញ ១ ស្រូវផ្កា ១ ស្រូវកន្ទុយ ១ ស្រូវនាងខៅ ១ ស្រូវស្លឹងមាន ១ ស្រូវផ្កាង់អំពៅ ១ . . . . . ៗ

**ពូជ** : ស្រូវដែលគេសម្រិតសម្រាំងរើសទុកដោយឡែក មិនឲ្យច្រឡូកច្រឡំនឹងស្រូវធម្មតា ហៅថា ស្រូវពូជ ។

**របៀបធ្វើស្រែ** មុនដំបូង វេលាដែលមានភ្លៀងធ្លាក់ចុះមកម្ដងៗ ត្រូវយកចបទៅទប់ភ្លឺស្រែទាប ៗ ឬ រង្វះកុំឲ្យហូរទឹកចេញពីក្នុងស្រែបាន លុះមានទឹកល្មមភ្ជួរហើយ ក៏ចាប់ភ្ជួរត្រឡប់ដីក្រោមជាលើ (ហៅតាមអ្នកស្រុកថា ភ្ជួរដាស ឬ រែស្រដី) ត្រូវទប់ទឹកឲ្យលិចអាចម៍ដីជានិច្ច ដើម្បីឲ្យស្អាប់ស្មៅ ។

**របៀបសាប** – មុនដំបូងគេយកពូជទៅត្រាំទឹកទុកចំនួន ២ - ៣ ថ្ងៃ រួចលើកដាក់លើគោកទុកឲ្យមានពន្លកហើយចាប់ធ្វើថ្នាល ត្រូវរកដីជិតផ្ទះឬទីដែលសម្បូរដីជាតិច្រើនត្រូវភ្ជួរត្រឡប់ដីដែលភ្ជួរម្ដងហើយ ជាលើកទីពីររួចរាស់ដោយរនាស់ឲ្យរាបស្មើ ទីបំផុតគេធ្លាក់ធ្មេញរនាស់ឡើងលើរាស់ក៏ទទឹងៈមរនាស់ម្ដងទៀតរួចភ្ជួរធ្វើជាចង្អូរសណ្ដានព្យួរជៀត ឃ្លាតចំនួនពីរម៉ែត្រពីគ្នា ដើម្បីឲ្យទឹកហូរទៅតាមចង្អូរនោះ រួចយកស្រូវពូជទៅព្រោះបាចរាយក្រោយ ថ្នាលដែលបាចគ្រាប់ស្រូវហើយ ត្រូវរក្សាកុំឲ្យទឹកហូរចូលក្នុងរវាង ៤ - ៥ ថ្ងៃ ដើម្បីទុកឱកាសឲ្យគ្រាប់ស្រូវចាក់ឫសដុះត្រយ បើបណ្ដោយឲ្យទឹកហូរចូលនឹងរលួយគ្រាប់ស្រូវខូចនាំឲ្យដុះមិនបានល្អ សូម្បីមានភ្លៀងធ្លាក់ច្រើនក្នុងរវាង ៣ - ៤ ថ្ងៃដែលសាបហើយ ថ្មី ៗ ត្រូវប្រឹងបាចទឹកចេញពីថ្នាល ឲ្យទាល់តែរីងទៅគគោកៗ លុះដល់

សំណាបនោះដុះល្អតវែងបានលិចសត្វចាបលលកហើយ សឹមបញ្ចូលទឹកឲ្យពេញទំហឹងចុះ តែត្រូវរាំងកុំឲ្យគោក្របីស៊ី ជាហេតុនាំឲ្យអន់សំណាប ៗ សំណាបដែលសាបហើយ បើស្រូវស្រាលក្នុង ១៥ ថ្ងៃ អាចនឹងដកស្ទូងទៅបាន បើស្រូវធ្ងន់ពី ២០ ថ្ងៃដល់ ៣០ បេះតែដកស្ទូងបាន ៗ

**របៀបធ្វើដីស្ទូង** — កាលបើសំណាបល្មមនឹងស្ទូងបានហើយ ក៏ចាប់ដកសំណាបចងជាកណ្ដាប់កាត់ចុងចេញ តែមិនត្រូវកាត់ឲ្យដល់បណ្ដូលសំណាបនោះទេរួចទៅទុកក្នុងទីដ៏ត្រូវ ៗ នៅវេលាថ្ងៃទី ១ គេចាប់ដកសំណាបរួចហើយ ព្រឹកឡើងថ្ងៃទី ២ ចាប់ភ្ជួរដីស្រែដែលភ្ជួររួចម្ដងហើយនេះ ការភ្ជួរនោះទៀត ត្រូវលៃមើលបើស្រែតូចល្មមស្ទូង ១ ពេលព្រឹកដល់ថ្ងៃត្រង់ហើយ សំខ្ទួនស្ទូងពីរពេលបានហើយ ត្រូវភ្ជួរពុះពាក់កណ្ដាលជាពីរពេល សូម្បីស្រែធំលើសជាងនេះក៏ត្រូវលៃតាមរបៀបនេះដែរ ដើម្បីទុកសម្រាកកំឡាំងសត្វពាហនៈផង អ្នកស្ទូងបានស្ទូងពីព្រឹកផង ហើយតាំងបានសម្រាកកំឡាំងនៅវេលាម៉ោង ១២ ថ្ងៃត្រង់ផង ៗ ការភ្ជួរលើកទីពីរនេះ ភ្ជួររួចត្រូវរាស់ឲ្យរាបដីដើម្បីនឹងស្ទូងបានស្រួល ៗ

**របៀបចាប់ដើមពូង** — បុកណាមានពិធីសែនព្រេនផង គឺថ្ងៃដែលចុះស្ទូងជាដំបូងបង្អស់ គេដកសំណាប ៣ កណ្ដាប់យកទៅដាក់លើកញ្ជើបូចផ្អើររួចយកផាហ៊ុមប្ដុំសំពត់ហូលមករុំព័ទ្ធកណ្ដាប់ ទុកឲ្យសល់តែក្បាលកណ្ដាប់

ហើយសម្លាប់មាន់សំបុរខ្មៅ យកទៅស្ងោរទាំងមូល រួចរៀបប្លាយចំណី ត្រីសាប៉ដាក់ចាន - ស្លាក យកមកដាក់តល់ទុកក្នុងរានជាសមគួរ ទើបអញ្ជើញ ចាស់ៗផ្ទះក្បែរខាងមកជួយអំពាវនាវសែនព្រេន វេលាដែលរៀបចំសព្វ គ្រប់ហើយ ឯចាស់ៗមកជួបជុំហើយ ក៏យកធ្យូងថ្នាំងលាយទឹកប្រេង ដូងដាក់ក្នុងចាន ១ ដាក់តល់ទុកក្បែរស្លាក រួចតាំងដុតទៀនតាំងប្រតិស្ឋ-អធិដ្ឋាន សម្បូងសន្រ្តីងថា " ហ៊ឹៗ ថ្ងៃនេះ ថ្ងៃជាពេលាល្អ ភូមិ ករ ព្រះធរណី រៀបចាប់ដើមតួផងជាដំបូងក្នុងឆ្នាំនេះ សូមឲ្យល្អដាក់ចុះដុះ ឡើង ល្អដូចស្លោខ្មៅដូចមរ បានគ្រាប់ទាំងគៅទាំងចាំង កុំឲ្យស្លក ស្លក " ចាំបែបនេះជាគំរប់ចីជង រួចទើបយកប្រេងលាបក្បាលកណ្ដាប់ ទុកសន្សំរង់ ១៥ នាទីទើបចាក់បែងរៀបបរិភោគ ៗ មុននឹងបរិភោគ គេយកមាន់ស្ងោរមកបេះយកស្លាបទាំងពីរ ជើងទាំងពីរនឹងក្បាល ១ ទុក ដោយឡែក លុះបរិភោគរួចហើយ ក៏យកជើងស្លាបនឹងក្បាលមាន់ខ្ចប់ យកទៅស្រែ នៅវេលាចាប់ស្ទូងដំណាតដំបូងនោះ គេកប់កញ្ចប់នោះ នៅគល់សន្ទូង (បែបនេះមានតែក្នុងសម័យបុរាណ សព្វថ្ងៃនេះមិនសូវ មាន) ។ អ្នកស្ទូងត្រូវពិនិត្យមើល បើដីមានដីជាតិច្រើនត្រូវស្ទូងឲ្យ រនើលៗ បើមិនសូវមានដីជាតិស្ទូងឲ្យញឹកបន្តិច ហើយត្រូវស្ទូងពីលើ ខ្យល់មុន ដើម្បីកុំឲ្យសំណាបឬសំណាក់ទៅប៉ះសន្ទូងដែលស្ទូងថ្មីៗ ។ នៅវេលាដែលស្ទូងរួចហើយ ខ្សោហ៍មើលថែសន្ទូងញយៗ កុំឲ្យគោ

ក្របីស៊ី នាំឲ្យអន់សន្ទូងជុះមិនល្អ ហើយមើលថែទាំទឹកឲ្យមានជានិច្ច កាលបើសន្ទូងមានដងដើមបែកគុម្ព មានបង្កើមចេញជាគ្រាប់ មានគួរសំយុងចុះ ទុំក្រហមមួយៗហើយ ត្រូវបង្ហូតទឹកចេញឲ្យរីងអស់ ។

**អំពីកណ្ដៀវសម្រាប់ច្រូតស្រូវ** ៖ វត្ថុដែលមានស្លាប, ថ្ម និងគោលហៅថាកណ្ដៀវ ។ គោល: ធ្វើឲ្យមានរង្វង់មូលបន្តិច តែមិនជាប់គ្នាទេ គ្រាន់តែឲ្យមូលសណ្ឋានថ្មសន្ទូច, ខាងចុងគោលឆ្លាក់ជាក្បាច់រចនាផ្សេងៗ ហើយលាបលនដោយធាតុហិង្គុល ឬម្រ័ក្សណ៍ ជាក្បាច់ពងគ្រីបុជាផ្កាច័ន្ទទ៍ ។ ស្លាប: ធ្វើពីមែកឈើតូចៗ រើសយកឈើដែលមានសាច់ស្វិតមានមែកត្របែកទឹងឆ្អងជាដើម ត្រូវរើសមើលមែកដែលល្មមធ្វើស្លាបកើត ហើយកាប់យកមករោលភ្លើង ពត់ជារង្វង់រចនាបង រួចទុកហាលថ្ងៃឲ្យស្ងួត ទើបយកមកបំពងទឹងកាំបិតឲ្យមូលល្អ រួចបោះវន្ធបណ្ដាយដង ត្រង់គល់ស្លាបទុកសម្រាប់ស៊កថ្ម ។ ថ្ម: ថ្មកណ្ដៀវធ្វើពីលោហធាតុ ( ដែក ) យកដែកដំឲ្យសំប៉ែត មានខ្នងកោងបន្តិច ធ្វើធ្មេញវែងខ្លីៗ ដូចជាធ្មេញសត្វកណ្ដុប, រួមគោល, ស្លាបនិងថ្មសម្ពន្ធចូលគ្នាហៅថា "កណ្ដៀវ" ។

**របៀបច្រូត**: មុននឹងច្រូតត្រូវយកឈើឬឫស្សីប្រវែង ៩-១០ ម. ទៅផ្ដេកឲ្យស្រូវដួលរាបស្មើ ដើម្បីឲ្យស្រួលដល់ការច្រូត ។ មួយទៀតក្នុងរដូវច្រូត មានទឹកសន្សើមធ្លាក់អ្នកច្រូតមិនត្រូវច្រូតហើយចងជាកណ្ដាប់

ភ្លាមទេ ត្រូវហាលឲ្យស្ងួតសិនចង ហើយដឹកជញ្ជូនទៅរៀបជាស្ទឹមទុកក្នុងរោង បើទុកនៅទីវាលត្រូវរកកន្ទេលឬស្លឹកគ្រប នៅវេលាដែលមានភ្លៀងម្តងៗ ដើម្បីកុំឲ្យគ្រាប់ស្អុយបុកបាក់អង្ករ ។ ការយកគ្រាប់ស្រូវប្រើវិធីបែនដោយជើងក៏បាន បញ្ជាន់ដោយជើងក្របីគោក៏បាន លុះបានជាគ្រាប់ស្រូវហើយ ត្រូវយកទៅរោយនឹងខ្យល់ ឲ្យចេញកំទេចកំញ៉មនឹងគ្រាប់ស្កកស្កុ នៅសល់តែគ្រាប់ល្អៗ ។ ការយកគ្រាប់ស្រូវដាក់ជង្រុក មុននឹងយកស្រូវដាក់ជង្រុក ត្រូវហាលឲ្យស្ងួតសិនដាក់ ដើម្បីកុំឲ្យខ្មូតស៊ី នេះចំពោះតែស្រូវដែលទទឹក បើស្រូវដែលស្ងួតហើយមិនបាច់ហាលក៏បាន ។

រឿងនេះ អ្នករៀបរៀងធ្លាប់ធ្វើដោយខ្លួនឯងឥតមានសួរគេទេ ។

## របៀបស្រូវពព្រោះ

បរិយាយខាងដើម នៃរបៀបស្រូវពព្រោះនេះ ទើបនឹងកើតមានរវាង ៨០-៩០ ឆ្នាំប៉ុណ្ណោះ ។ មានសេចក្តីដំណាលថា មានតាម្នាក់ឈ្មោះទង គាត់នៅឃុំអន្ទោង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ តានេះឯងកាលគាត់នៅពីក្មេង អាយុប្រហែល ២៨ ឆ្នាំ គាត់មានប្រពន្ធហើយ ទទួលឆ្នាំនោះរាំងធ្វើស្រែសន្ទូងមិនកើត ។ គាត់ដើរចុះឡើងរកស្រូវទទួលទាន ពេល ១ គាត់ដើរកាត់វាលស្មៅស្មោងក៏បែកគំនិត គិតធ្វើស្រូវពព្រោះល្បងមើល ទើបគាត់កាប់ស្មៅឲ្យរាបហើយដុតភ្លើងចោល

វេលាដែលខែមានទឹកភ្លៀងទឹកធ្លាក់ម្ដងៗគាត់តាំងភ្ជួររាស់ដីចំនួន១ហិកតារ យកពូជទៅព្រោះ ក៏បានដុះមានផ្លែផ្កា ដូចបំណង ។ តាំងពីពេលនោះមក គាត់ក៏ចាប់កាន់ដីឲ្យបានច្រើន ទើបផ្ដើលដល់អ្នកស្រុកមកសុំដីកលកនធ្វើស្រែពង្រោះគ្រប់គ្នាឡើង តាមបែបគាននងដែលគាត់បានធ្វើមក ហើយនោះ សឹងបានផលចំរើនកប់ពាន់ហ៊ឹនរៀល ដរាបមកដល់សព្វថ្ងៃនេះ ។

បរិយាយប៉ុណ្ណោះ ទុកជារឿងព្រេងក្នុងបច្ចុប្បន្ន ។

**របៀបស្រែព្រោះ** ស្រែព្រោះនេះគេចាប់ធ្វើតាំងពីខែចេត្រឬខែពិសាខ ដំបូងអង្គស់ គេចាំមើលទឹកភ្លៀង បើមានភ្លៀងច្រើនល្មមសើមដីចុះទៅក្រោមចំនួន ៣០ - ៤០ សង្ទីម៉ែត្រ ទើបចាប់ភ្ជួរហាលដី ត្រឡប់លើជាក្រោម ដោយនង្គ័ល លុះភ្ជួររួចហើយ ១០ - ២០ថ្ងៃដើម្បីឲ្យងាប់ស្មៅ ។

**ពូជ:** គ្រាប់ស្រូវដែលបំរុងទុកព្រោះ ហៅថាពូជ ។ ពូជពង្រោះនេះ គេយកតែពូជស្រូវឈ្មោះទឹកទៅព្រោះ ព្រោះធញ្ញជាតិនេះវេលាដែលដុះមានបណ្ដូលត្រយសន្ទុកហើយ បើទុកជាទឹកឡើងពុះពារមានកំពស់ ២ - ៣ ម ធញ្ញជាតិនេះតែលូតផុតលើទឹកជាដរាប បានជាគេហៅថាស្រូវឈ្មោះទឹកឬស្រូវឡើងទឹក ។ ពូជនេះ មុននឹងយកទៅបាច ត្រូវយកទៅត្រាំទឹកពីរបីថ្ងៃ ហើយលើកមកទុកលើគោក ។

**របៀបធ្វើដីព្រោះ** កាលបើពូជបំរុងព្រោះមានសព្វគ្រប់ហើយ ត្រូវភ្ជួរដីដែលភ្ជួរម្តងហើយនោះ ១ លើកទៀត ហើយត្រូវយកពូជទៅព្រោះ ៗ វេលាព្រោះហើយភ្លាម ត្រូវយករនាស់រាស់លុបគ្រាប់ស្រូវដើម្បីកុំឲ្យចាបស៊ីផង ឲ្យរាបអាចម៍ដីផង ក្នុងដី ១ ហិកតារត្រូវព្រោះមិនចាំបាច់ធ្វើភ្លឺលើកទំនប់ឡើយ តែគេត្រូវធ្វើស្នាមភ្លោះ ទុកបង្ហូរទឹកទៅរកស្ទឹងបឹងទន្លេ ក្នុងពេលដែលទើបនឹងព្រោះបានពីរបីថ្ងៃមិនទាន់ដុះ ហើយមានភ្លៀងជន់ច្រើន ៗ

# គ្រឿងប្រដាប់ធ្វើ

វិធីធ្វើស្រូវព្រោះ ត្រូវមាននង្គ័ល, រនាស់, ទឹម, ពួរ, ខ្សែ, ខ្សែទាម, កន្ទុះនឹងចប ៗ នង្គ័លសម្រាប់ភ្ជួរដី, រនាស់សម្រាប់រាស់ដីឲ្យរាប, ទឹមសម្រាប់ទឹមដាក់លើកគោក្របី, ខ្សែសម្រាប់ចាប់គោក្របីភ្ជួរ, ខ្សែទាមសម្រាប់បង់ទឹមពាំទៅក្រោមកគោក្របី ហើយចងភ្ជាប់ទៅចុងទឹម, កន្ទុះសម្រាប់ខ្ទះច្រមុះក្របីឬគោ ៗ

នង្គ័លសម្រាប់ភ្ជួរដីព្រោះ មានរបៀបខុសពីនង្គ័លភ្ជួរស្រែស្ទូងបន្តិច គឺមានយាម, ដងភ្នៀងដូចគ្នា ប៉ុន្តែយាមគេយកឈើប្រវែង ៨០ សង់ទីម៉ែត្រទំហំ ១០ សង់ទីម៉ែត្រ ៤ ជ្រុង ហើយឈូសឲ្យខាងចុងតូចជាងខាងគល់បន្តិច រួចយកឈើប្រវែង ៤០ ឬ ៥០ សង់ទីម៉ែត្រទំហំ ៤ សង់ទីម៉ែត្រមូលមកដាប់បញ្ចូលទុកសម្រាប់លើកបង្ហិលចុះឡើង ខាងគល់យាមដាប់

បញ្ចូលទៅក្នុងក្អៀង ។ ក្អៀងនង្គ័លសម្រាប់ភ្ជួរដីស្រែ មិនចាំបាច់រកឈើមានដុំធំទេ គ្រាន់តែយកឈើមានទំហំ ៣០ ឬ ២០ សង់ទីម៉ែត្រ មូល មកចាំងប្រាស់ទឹងដឹង ឬ ប៉ុវបៅ ឲ្យតែមានទ្រង់ទ្រាយដូចជាស្នាប ក្អៀងបន្តិច ហើយគេយកស្នាបដែកមានទ្រង់ទ្រាយដូចជាស្នាបក្អៀងដែរ មកពាំងពុះបោះកន្លាស់ដែកពីមុខសាច់ឈើ ដើម្បីកុំឲ្យស្រឹកសាច់ឈើ ហើយបញ្ចូលផ្លែដែក ឬ ផាលដែក សម្រាប់ឲ្យមុតដីតែប៉ុណ្ណោះបាន ។ ដងនង្គ័លប្រវែងជាង ៣ ម៉ែត្រ វាងគល់សំប៉ែតទំហំបន្ទា ១៣ - ១៤ សង់ទីម៉ែត្រ ទោលទំហំ ៣-៤ សង់ទីម៉ែត្រតូចទៀវទៅខាងចុង ហើយងរឡើងបន្តិច រួមយាម, ក្អៀង, ដង ហៅនង្គ័ល ។ (តាមច្បាប់ដើមមានគូរគំនូរនង្គ័លសម្រាប់ភ្ជួរដីស្រែ ) ។

៦ ប្រដាប់ប្រដា ដូចជារនាស់, ទឹម, ខ្សែ, ខ្សែទ្រាម សូមមើលក្នុងរបៀបធ្វើស្រូវស្រា ។

ប្រពៃណីបុរាណ វេលាដែលព្រោះហើយស្រូវដុះឡើងរពង ១ ហត្ថពីដី ទើបគេតាំងបាយ៉ាប រួចដាក់នំចំណីឬតួតបាយ ៤ ដុំដាក់បន្ទាស ហើយអុជធូបថ្វាយម្រេញគង្វាល ដោយមានពាក្យថា " បា អស់លោកអ្នកនៅរក្សាទឹកដីនេះ ឥឡូវយើងខ្ញុំមកនៅជ្រកកោនទីងលោក សូមឲ្យលោកមើលក្ដាម, កណ្ដុរ, កណ្ដូប, ជាកូនចៅលោកកុំឲ្យបៀតបៀនកាត់ស្រូវស៊ីស្រូវ យើងសូមថ្វាយបាយ៉ាបនេះជាបន្ទាល់ " ។

**របៀបធ្វើចាយ៉ាប** យកចំរៀកឫស្សីតូច ៗ មកខ្ចាស់ជាក្រឡាចត្រង្គ ទំហំ ២០ សង់ទីម៉ែត្រ ៤ ជ្រុង ហើយយកឫស្សីមកពុះពីខាងចុងជា ៤ ចំរៀក រួចយកចងត្រង់ជ្រុងចាយ៉ាបទាំង ៤ ហើយយកទៅដោតត្រង់ក្បាលដី ។

វេលាដែលស្រូវផុះហើយ មានទឹកទន្លេចូល អ្នកស្រែព្រោះអស់មានវិធីធ្វើអ្វីទៀតហើយ លុះដល់ទឹកស្រក គ្រាន់តែថែរក្សា កុំឲ្យគោក្របីលុកលុយស៊ីស្រូវនោះ ៗ ដល់វេលាស្រូវទុំត្រូវប្រើវិធីច្រូត, តែរបៀបច្រូតឥតមានយកឈើឬឫស្សីទៅផ្តេកឲ្យដូចជាស្រូវស្ទូងនោះទេ គ្រាន់តែពិនិត្យមើលស្រូវទុំល្មមច្រូតហើយ ក៏បាច់ច្រូតតែម្តងក្នុងរវាងខែមាឃ គេបាច់ច្រូតស្រូវព្រោះនេះ ឯរបៀបច្រូតនិងរបៀបយកគ្រាប់ស្រូវ នឹងរបៀបយកស្រូវដាក់ជង្រុក សូមមើលក្នុងរឿងស្រូវស្រា ៗ (រឿងនេះបានសួរដោយច្បាស់លាស់ពីឈ្មោះ ទូច-ផន នៅភូមិអន្លង់រាជ, ឃុំត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង) ។

# សុភាសិត ភាគទី ២

លោក ព៉យ - ប៊ុក ក្រមការ រៀបរៀង

( តទៅ )

............

## ពាលវគ្គ

១ – បុគ្គលមុខរីកដូចបទុម ពាចាពោលសមដូចខ្លឹមច័ន្ទន៍ អណ្តាតទឹកឃ្មុំចិត្តពិសព័ន្ធ គប្បីកុំជាន់ឈរនៅជិត ។

២– បុគ្គលពាលនៅក្នុងទ្រូងមារ កំលេសពានភារដូចព្យុះព្រៃ តែងតែត្រូវខ្លួនគ្មានប្រណី ដល់ក្សយជន្មាទៅអបាយ ។

៣ – គំនរភ្លើងមិនឆ្អែតទុក្ខា សមុទ្រជលសាមិនឆ្អែតទន្លេ បុគ្គលចិត្តលោភគ្មានទំនេរ សម្បត្តិប្រកាន់ឡើងមិនចេះឆ្អែត ។

៤ – មច្ឆាត្រីឆ្កោរស៊ីកូនឯង កូនបេកប្រាជ្ញចែងស៊ីមេវា បុស្សីបចោសុំផ្លែតែងមរណា ប្រាបរោកតែងសម្លាប់ជនពាល ។

៥ – ពស់ទឹងមិនស្មើដំរីចុះប្រេង ដំរីវង្វេងមិនស្មើរាជសីហ៍ ស្តេចទ្រង់ព្រះក្រោធខ្លាំងគគប៉ី ឆេះមិនប្រណីអប្រិយភូមិកព ។

៦ – មនុស្សលោកនេះឧបាទាន ដណ្តើមឈ្មោះពានត្រូវម្នាក់ឯង ដូចបុគ្គលខ្វាក់យល់ជាក់ស្តែង ស្ទាបដំរីរើងទាស់ទែងគ្នា ។

៧ – បុគ្គលពាលសុខបច្ចុប្បន្ន ប្រកបទុក្ខដល់អនាគត តែពួកសប្បុរសទុក្ខប្រាកដ ដល់អនាគតបានឋានសួគ៌ ។

៨ — ធនពាលដល់ពេលកើតកលិយុគ   ទេវតាឲ្យទុក្ខចាំផ្តា
ពួកប្រាជ្ញសប្បុរសកាន់ធម្ម  ដល់ពេលទុក្ខាទេវតាជួយ ។

៩ — ចិត្តលោភដូចសាគរជេងធំ   ខ្ទេប្រដុំពុំស្កប់ស្កល់   បើមាន
ទ្រព្យច្រើនហៅសេសសល់  គង់កែកំបូកលះនៅជាក្រ ។

១០ — នៅជិតមនុស្សពាល   ដូចភ្លើងឆេះរាលឆេះព្រៃព្រឹក្សា
ដូចសត្វមានពិស  ក្លាខ្លាំងពណា  ដូចយក្សមនុស្សា តែងមានទោសទុក្ខ ។

១១ — ព្រៃគ្មានសត្វជិត   ប្រទេសឥតបណ្ឌិត   ទ្វីបឥតសាសនា
គ្រឹះឋានឥតបុត្រ  ស្រុកគ្មានជាតិជា  មេឃឥតចន្ទ្រា   សូន្យចក្រពាឡ ។

១២ — ធម្មតាកែកមិនស្គាល់រសសម្ម   មេអំបៅរមិនស្គាល់រសបុប្ផា
ពួកល្ងង់ខ្លៅមិនស្គាល់រសធម្មា   ឬបាបពាលាមិនស្គាល់រសបុណ្យ ។

១៣ — ធម្មតាឆ្កែកាច   ស៊ីកត្រចៀកងាយ   តែងឈ្លោះទាស់គ្នា
ក្រពើកំបុត  កន្ទុយមហិមា  កាចឆុតលោកា  ត្រីបាស្អីងកែក ។ ពាល
តែងរុកគុន  មិនមានចិត្តស្លូន  តែងស្តីផ្តែក  ពុំដែលឃើញស្ងាត់  ដាល់
តបច្បាក់បែក  ដំបងដងកែក  ទាល់តែវិនាស ។

១៤ — ធម្មតាខ្លាអាស្រ័យឈ្មោះក្លាន   ចំពាក់កមានផ្កាយពោះគុក
កិច្ចការទុច្ចរិតអាក្រក់លាមក   មានតែឲ្យទុក្ខកាលវេលា ។

១៥ — សៀវភៅពេញទូ មិនដែលស្គាល់គិតគូរ  យកមកទស្សនា
មានកំណប់ទ្រព្យ អសារឥតការ  អក្ខុយធម្មា  មិនស្គាល់ទានសីល ។

នៅជិតបណ្ឌិតពិត អន្ទិយចូលជិត ព្រហ្មទណ្ឌមិនស្គាល់ នៅជិតព្រះពុទ្ធ

សាសនាមណ្ឌល មិនមានកមល បង់ស្លាប់ទទេ ។

## មិត្តវគ្គ

១ – មេឃមីរស្រទុំ កស័ចុះសម អាប់យសសក្តា អ្នកនៅម្នាក់ឯង

កុំគិតសង្កា ញាតិមិត្តអាត្មា ដកឃ្លាឃ្លាតឆ្ងាយ ។

២ – មិត្តឯណា ហាមឃាត់ការអប្រិយ ត្រង់ការស្ដុស្ដីចំដាស់តឿន

ក្នុងពេលវិបត្តិមិនបោលភៀន មិត្តនោះទើបហៅថាមិត្តពិត ។

៣ – កុំសេពគប់មិត្ត ចិត្តពាលបោរពិត កោងកាចអប្រិយ

អ្នកលេងល្បែងភ្នាល់ អាំងអ្នកលេងស្រី តែងអាប់សួស្តី ថយថោក

ស័ក្តិយស ។ អ្នកសេពសុរា ស្ងោកច្រាក់ទ្រព្យា ញាតិដទៃសោះ

បញ្ញាតប្រវ៉ៃ លាក់ឥតបរស់ ជាមិត្តនាំអសប្បុរស នាំទុក្ខមកឲ្យ ។

៤ – មិត្តណា មានមាត់ ផ្អែមចិត្តជូរចត់ កំណាបៀតសោះ

និយាយប្រស្រ័យ កាលហួសផុតអស់ អនាគតសោះ ពាក្យខុសប្រ-

មាណ ។

៥ – ជាតិច្រែតាំងយូ ពេលក្តៅក្រៀងស្ងួ បើកបាំងជួយញាតិ

ពេលថ្ងៃសុខសាន្ត នៅស្ងៀមបិទស្អាត ដូចមិត្តមិនឃ្លាត ជួយទ្រៀត

ដោះទុក្ខ ។

៦ – មិត្តល្អឲ្យសុខ បាបមិត្តឲ្យទុក្ខ គប់ទំនេវក់ មិត្តល្អក្រមាន ខ្ពស់ទាបយ៉ាងណា តែងយកអាសា ដាស់តឿនខុសត្រូវ ។

៧ – ប្រាជ្ញស្គាល់បាបមិត្តពេលមានទ្រព្យ ស្គាល់សំដីស័ព្ទប្រាជ្ញល្ងង់ ស្គាល់កាចស្លូតដោយភាពទ្រង់ ស្គាល់ថោកទាបវង្សដោយកិរិយា ។

## បកិណ្ណកវគ្គ

១ – អកត្តញ្ញូស្រេបដើមដៃ ជាតិសន្ដៃព្រៃតូចបង់ធំ ទន្ទ្រានខេត្តពាលកាចគំនុំ ដើមតែងពិតសមជនសុភាព ។

២ – ស្នាមជើងខូងកណ្ដាលភគបរិត ធ្ងន់អួសកែងគិតជនទោសៈ ធ្ងន់ចុងម្រាមជើងជនមោហៈ ស្នាមជើងកងចក្រសូត្រកិលេស ។

៣ – កន្ទារខ្មោចឆ្ងាយ លំបាកកាយសត្វវេលា សមុទ្រវដ្ដសង្សារ ឆ្ងាយណាស់សារមើលមិនយល់ ។ សាសនាបាំងពពក ជាតិពន្លក មើលមិនដល់ បែកផ្សែងល្វិតមណ្ឌល គួរគិតកលរកពន្លឺ ។

៤ – អានសៀវភៅមានប្រយោជន៍ពិត បុរាណបណ្ឌិតបច្ចុប្បន្ន យកមករិះគិតប្រសើរលន់ ប្រាជ្ញាពេកពន់គ្មីសែងស្មាន ។ កុំគិតតែប្រទេសអាត្មា ត្រូវយកប្រាជ្ញាក្រោលសំអាង លោកធាតុទាំងមូលត្រូវស្គាល់ជាង ស្ទាបគេដាងក្ដីពេញចក្រវាឡ ។

(មានត)

# ស័ព្ទបារាំងប្រែជាខ្មែរ

របស់

គណៈកម្មការវប្បធម៌

## ហ្លួងគិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

---

Service d'Immigration = ក្រុមជនចូលស្រុក

Inspection = អធិការដ្ឋាន

Cantonnement = ខណ្ឌ

Division = ផ្នែក

Triage = ការស្រាស់ជ្រើស

(14 5-48)

Directeur = ចាងហ្វាង

Surveillant général = អគ្គានុរក្ស

Surveillant = អនុរក្ស

Economat = ទីអ្នកផ្គត់ផ្គង់

Econome = អ្នកផ្គត់ផ្គង់

Lingère = ធោវិកា

Lingerie = ធោវនដ្ឋាន

Linge = ធោវនពស្ត្រ

Dortoir = សយនដ្ឋាន

Douche = នហានដ្ឋាន, កន្លែងងូត, ស្នានដ្ឋាន

Cuisine = ផ្ទះបាយ

Réfectoire = ភោជនដ្ឋាន

Salle de consigne = សាលទណ្ឌកម្ម

Salle de professeurs = សាលសាស្ត្រាចារ្យ

Bibliothèque = បណ្ណាល័យ

Cours supérieur spécial = ថ្នាក់ឧត្តមដ្ឋានពិសេស

(Le 16-5 48)

Bon pour délivrer . . . valabl au . . . . à prendre livraison chez . . . à M . . . autorisation de transport de . . . . commerçant à . . . est autorisé à transporter = បណ្ណសម្រាប់ បើក . . ត្រូវបានដល់ថ្ងៃទី . . . យកអំពីផ្ទះ . . . ឈ្មួញនោះ . . . បានអនុញ្ញាតឲ្យដឹកនាំ

Acte de transaction កិច្ចសម្រះសម្រួល

Procès- v·rbal N° . . . a été dressé le . . . par M . . . . contre le nommé . . . domicilié . . . pour . . . infraction prévue et réprimée par . . . . . et passible des peines suivantes . . . .

Pour éviter les suites judiciaires de linfraction ci-dessus, il a été convenu contre le . . . soussigné d'une part et le nommé . . . d'autre part d'un règlement transactionnel sur les bases suivantes

1er versement par . . . d'une indemnité transactionnelle de . . .

2e Le contrevenant . . . .

## សេចក្ដីប្រែ

សេចក្ដីកត់ហេតុលេខ . . . ចុះថ្ងៃទី . . . លោកធ្វើចំពោះឈ្មោះ . . . នៅនា . . . ដោយហេតុបទល្មើសដែលមានត្រាទុក ព្រមទាំងកំណត់ទណ្ឌកម្មកង . . . ហើយត្រូវទទួលទោសដូចតទៅនេះ ។ ដើម្បីចៀសវាងកុំឲ្យមានការប្ដឹងដល់តុលាការ ក្នុងបទល្មើសខាងលើនេះបានព្រមព្រៀងគ្នារវាងលោក . . . ដែលមានចុះហត្ថលេខាខាងក្រោមនេះម្ខាង ហើយនឹងម្ខាងទៀតឈ្មោះ . . . ធ្វើកិច្ចសំរុះសំរួលជាដាច់ស្រេច មានសេចក្ដីដូចតទៅនេះ :

១) ឈ្មោះ . . . ត្រូវបង់ប្រាក់បំណាច់សំរុះសំរួលចំនួន . . . ៛

២) អ្នកល្មើស . . . ។

Certificat d'importation valable uniquement pour les marchandises à quai = វិញ្ញាបនប័ត្រនៃការនាំចូលប្រើបានតែទំនិញនៅផ្លាក់ពង់ ។

Certificat (provisoire) relatif à l'importation des marchandises étrangères = វិញ្ញាបនប័ត្រ (បណ្ដោះអាសន្ន) ដែលទាក់ទងនឹងការនាំទំនិញចូលមកពីប្រទេសក្រៅ ។

Titulaire = អ្នកទទួលវិញ្ញាបនប័ត្រ

Adresse = ទីលំនៅ

Nature des marchandises = ប្រភេទទំនិញ

(2-7-49)

Remise des certificats épuisés ou périmés = ការប្រគល់វិញ្ញា-
បនប័ត្របានប្រើអស់ហើយ ឬ ផុតកំណត់ហើយ ។

Les certificats épuisés ou périmés, que les importateurs renoncent à utiliser devront être remis immédiatement au secrétariat d'Etat au C. I. R. = វិញ្ញាបនប័ត្រទាំងឡាយ ដែលប្រើអស់ហើយ, ផុតកំណត់ហើយ ឬ ដែលអ្នកនាំទំនិញចូលលះបង់លែងប្រើប្រាស់នោះ ត្រូវប្រគល់ភ្លាមទៅរដ្ឋលេខាធិការដ្ឋានខាង ព.ឧ.ក. ។

Les importateurs qui n'observaient pas ces prescriptions s'exposeraient à se voir refuser toute délivrance, de nouveaux certificats = អ្នកនាំទំនិញចូល ដែលមិនប្រតិបត្តិតាមបញ្ញត្តិនេះ មិនអាចសុំវិញ្ញាបនប័ត្រថ្មីទៀតបានឡើយ ។

Le S. E. C. I. R. certifié que l'opération ne donne bien à la délivrance des devises étrangère- = លោក រ.ល.ព.ឧ.ក. បញ្ជាក់ថា ការប្រតិបត្តិការនេះ ជាការមិនបញ្ចេញរូបិយប័ណ្ណបរទេសឲ្យទេ ។

*Prorogation de validité* = le présent certificat cessera d'être valable à expiration du délai de validité mentionné ci-dessus sauf si la prorogation a été acceptée par le S. E. C. I. R. = ការបន្ទាយពេលអនុញ្ញាត = វិញ្ញាបនប័ត្រនេះនឹងលើកលែងត្រាទុកខាងលើនេះ វៀរលែងតែលោក រ.ល.ព.ឧ.ក. បានព្រមទទួលបន្ទាយពេលឲ្យ ។

Cette prorogation devra obligatoirement être demandée deux semaines un incins avant la date d'expiration du certificat = ការបន្ទាយពេលនេះ ត្រូវតែសុំពីរសប្តាហ៍ៈយ៉ាងតិចមុនផុតកាលបរិច្ឆេទនៃវិញ្ញាបនប័ត្រ ។

Prérogative = បុព្វសិទ្ធិ

(Le 6-7-48)

Permis d'exportatioı = លិខិតអនុញ្ញាតនាំចេញ

Permis de transit = លិខិតអនុញ្ញាតនាំកាត់

Demandeur = អ្នកសុំ

Numéro d'inseription au registre de commerce ou de la patente= លេខចុះបញ្ជីការជំនួញ ឬ ប៉ាតង់

Port ou Bureau duoanier d'entrée (pour transit seulement) = កំពង់ ឬ ប៉ុស្តិ៍គយចូល (សម្រាប់តែការនាំកាត់) ។

Port ou Bureau douanier de sortie = កំពង់ ឬ ប៉ុស្តិ៍គយចេញ

Mode d'exportation (route, chemin de fer, bateau...) វិធីនាំចេញ (ថ្នល់អយស្ម័យយាន, កប៉ាល់)

Destination définitive: Avant d'atteindre sa destination définitive le chargement devra transiter (hors d'Indochine) par... ទីទទួលជាស្ថាពរ: មុននឹងដល់ទីទួលជាស្ថាពរ, ការកំណត្រូវនាំកាត់(ក្រៅឥណ្ឌូចិន) តាម . . .

Nom du destinataire définitif = ឈ្មោះអ្នកទទួលជាស្ថាពរ

L'exportation devra être faite avant le .. = ការនាំចេញត្រូវធ្វើមុនថ្ងៃ . . .

Copie pour archive = លិខិតចម្លងទុកជាឯកសារ

Apurement par les services de l'administration des Douanes et Régie =

ការពិនិត្យសម្រេចនៃកដការគយនិងរដ្ឋាករ

La présent autorisation cessera d'être valable si elle n'a pas été utilisée dans les' delais pour les quels elle a été accordée. Elle peut être révoqnée à tout instant par ordre du serétaire d'Etat au C. I. R. = អនុញ្ញាតនេះ បើមិនប្រើក្នុងរយៈពេលដែលកំណត់ទុកទេនឹង ប្រើតទៅទៀតពុំបាន រដ្ឋលេខាធិការ ព.ម.ក. អាចបង្គាប់ ឲ្យបដិសេធអនុញ្ញាតនេះចោល ពេលណាក៏បាន ។

Elle n'est pas transmissible et doit être utilisée par le demandeur = អនុញ្ញាតនេះ អ្នកសុំត្រូវប្រើខ្លួនឯង និងឲ្យអ្នកដទៃជួសពុំបាន ។

Compagne d'appel des nations-unis en faveur de l'Enfance = ការឃោសនានៃសហប្រជាជាតិ ដើម្បីសង្គ្រោះកុមារ

Institut antirabique = វិជ្ជាឋានៈកំចាត់•មគ្គកភេគ

(Le 9-7-48)

Etat major = សេនាធិការ

Transmission = ក្រុមនាំសារ

Quartier général = ទីបញ្ជាការ (ទាហាន)

Compagnie des parachutistes = កងអនុសេនាធំនៃទាហានឆ័ត្រយោង

Commando = កងកុម្មង់ដូ (កងពិសេស)

Officier de liaison = នាយទាហានសម្ព័ន្ធ

Agent de liaison = ភ្នាក់ងារសម្ព័ន្ធ

Service extérieur = ក្រុមខាងក្រៅ

Services municipaux = ក្រុមកងការក្រុង-

Clinique ophtalmologique et oto-Rhino-Laryngologique = មន្ទីរ ចក្ខុ-កណ្ណៈ-ឃានៈ-កណ្ណរោគ

Médecin des Hôpitaux Psychiatriques = គ្រូពេទ្យឧត្តមវិជ្ជា វិកលចរិត

Infirmerie = គិលានដ្ឋាន

Anti = បដិប័ក្ខ Antirabique = បដិប័ក្ខឧម្មត្តករោគ

(Le Mardi 13-7-48)

Lever et immatriculer des terres = វាស់ចុះបញ្ជីដី

Concession = សម្បទាន

Plan = គ្រោងការ

Plan d'aménagement = ផែនទី (ប្លង់) រៀបចំដី

Plan d'alignement = ផែនទី (ប្លង់) រៀបជួរដី

Plan de lotissement = ផែនទី (ប្លង់) រៀបខ្ទង់ដី

Plan parcellaire = ផែនទី (ប្លង់) រៀបក្បាលដី

Parcelle = ក្បាលដី

Laboratoire de photo restitution = ទីពិសោធន៍កែតម្រូវរូបថត

Commission de bornage = គណៈកម្មការព្រំដី

Commission administrative = គណៈកម្មការរដ្ឋបាល

Plan topographique = ផែនទី (ប្លង់) ឋានលេខា

Lever par rayonnement = វាស់ដោយវិធីរស្មី

Lever par intersection = វាស់ដោយវិធីបន្ទាត់កាត់គ្នា

Lever par relèvement = វាស់ដោយវិធីសាដាខ

Lever par cheminement = វាស់ដោយវិធីបន្ត

Arpenteur-Dessinateur = វដ្ឋករ-ចិត្រករ

Peintre = វិចិត្រករ

Comité = គណៈកម្មាធិការ

Commission = គណៈកម្មការ

(Le vendredi 16-7-48)

Calquer = ផ្ទាប់ចម្លង

Papier à calquer = ក្រដាសផ្ទាប់ចម្លង

Recensement = ការជំរឿន

Recenseur = អ្នកជំរឿន

Papier carbone = ក្រដាសធ្យូង

Papier pelure = ក្រដាសស្តើង

Translucide = ថ្លង់

Transparent = ឈ្លេង

Opaque = ខ្វក់

Contrôle = ការត្រួត

Incompatible = ដែលមិនចុះសម្រុង

Prévoté militaire khmère = ក្រុមត្រួតទាហានខ្មែរ

Prévôt = នាយកត្រួតទាហាន

Poste militaire = ទីកងទាហាន

Brigade de police spéciale = កងប៉ូលិសពិសេស

Hiérarchie = លំដាប់ស័ក្តិ

Commandant = អ្នកបញ្ជាការ (សម្រាប់ឧត្តមសេនីយ៍)

អ្នកបង្គាប់ការ (សម្រាប់វរសេនីយ៍),

អ្នកកាន់កាប់ការ (សម្រាប់អនុសេនីយ៍)

Peloton = ពួកទាហាន

Patrouille = ល្បាត

Reconnaissance = ការឈ្លបយកការ (សម្រាប់ទាហាន)

(Le vendredi 23-7-48)

Exploitation = អាជីវកម្ម

Taxe sur le chiffre d'affaires = ភាស៊ីលើផលរបរ

Opération = ប្រតិបត្តិការ

Les importations = របស់នាំចូល

Liquidation de l'Impôt = ការលៃតម្លៃពន្ធ

Courtage = កំរៃជើងសារជំនួញ

Exploitant = អាជីវករ

Impôt sur le revenu = ពន្ធលើផលដើមទុន

Impôt sur les bénéfices = ពន្ធលើចំណេញ

Impôt = ពន្ធ

Taxe ភាស៊ី

Courtier = ជើងសារជំនួញ

Intermédiaire = អ្នកកណ្ដាល

Organisme = អង្គការ

Services = ការហាត់ខឿយ

Personne physique = រូបវន្តបុគ្គល

Mine = អណ្តូងរ៉ែ

Minerai = រ៉ែ

Jade = ថ្មយ៉ុក

Revue de l'Instituteur khmèr = ទស្សនាវដ្តីសម្រាប់គ្រូបង្រៀន

Inventaire = បញ្ជីសារពើភ័ណ្ឌ

Transaction = ការសំរុះសំរួល

Obligation du redevable = កាតព្វកិច្ចនៃអ្នកជាប់ពន្ធ

Meuble = គ្រឿងតុបតែង

Bien meuble = សង្ហារិម

Immeuble = អសង្ហារិម

Assiette de la taxe = មូលដ្ឋានអាករ

Fait générateur de la taxe = ការណ៍បណ្តាលឲ្យជាប់អាករ

Bonne foi = សុទ្ធចិត្ត

Mauvaise foi = អសុទ្ធចិត្ត

(Le 30 7-48)

Arbitre = អាជ្ញាកណ្តាល

Antiquité = បុរាណវត្ថុ

Formalité = ទម្រង់ការ

Modalité = បែបបទ

Le mémoire = សារណា

Décharge = ផ្ទេរបន្ទុក

Expert = អ្នកជំនាញ

La mémoire = ស្មារតី, សតិ

Le mémorandum = អនុស្សរណៈ

L'aide-mémoire = ជំនួយស្មារតី

Spécialiste = អ្នកឯកទេស

Spécialité = វត្ថុឯកទេស

Echange (de renseignements = ការផ្លាស់ប្តូរ (ព័ត៌មាន, ដំណឹង)

Dommages intérêts = ជម្ងឺចិត្ត

Collectivité = សមូហភាព

Façonner = ធ្វើមុខការ

(Le 3-8 48)

Bon sens = សុភនិច្ឆ័យ

Conscience morale = មនសិការ

La raison = វិចារណញ្ញាណ

Sous la présidence de = ក្រោមអធិបតីភាពនៃ

Statut commun = សហលក្ខន្តិកៈ

Marchand ambulant 2% = ឈ្មួញចរាចរពីរភាគរយៈ (២%)

Deux centième = ពីរភាគរយ

Savoir-vivre = សុជីវធម៌

(Le 6-8 48)

Actif net = សកម្មសុទ្ធ

Agio = អតិប្រមាណ

L'actif = សកម្ម

Le passif = អកម្ម

Inactif = និស្សកម្ម

Agiotage = អតិប្រមាណកម្ម

Acquisition — ការបាន, វត្ថុដែលបាន

Annuité — អនុសំវច្ឆរេត្យ

L'indice — លក្ខណ៍, សន្ទស្សន៍ (សន្ទ—ទស្ស)

Amortissement — ការរំលស់, ការបន្ថយ

(Le Mardi 10-8-48)

Positif — វិជ្ជមាន

Négatif — អវិជ្ជមាន

Constructif — ស្ថាប័ន

Pouvoir d'achat — សមត្ថភាពខាងទិញ

Affirmer — អះអាង

Confirmer — អះអាងបន្ថែម

Destruction — និស្ថាប័ន

La masse — ប្រជាករ

Amodiateur — អ្នកឲ្យប្រវាស់ដី ឬ ឲ្យជួលដី

Amodiataire — អ្នកទទួលប្រវាស់ ឬ អ្នកទទួលជួលដី (គេ)

Fermier — អ្នកជួលដីរបរ

Métayer — អ្នកទទួលប្រវាស់ដី

(Le vendredi 13-8-48)

Moteur électrique — គ្រឿងយន្តអគ្គិសនី

Radio — វិទ្យុ

Articles divers — របស់ផ្សេងៗ

Salle d'attente — សាលារង់ចាំ

(មានត)

# ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា

ហ៊ុនទិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

---

មានគណបក្ស ២ នៅគ្នាគឺៈ គណបក្សឈ្មោះគោលៈ ១ គណបក្សឈ្មោះបន្ទុយៈ ១ ទាំង ២ គណបក្សនេះ ធ្លាប់មានការទាក់ទងទៅមកនឹងនានាប្រទេសដែលនៅឆ្ងាយៗ ដូចជាពេមទឹងអ៊ីស៊ីប្តជាដើម ។ ក្នុងពេលពុទ្ធសករាជ ៥០០ ដែនដីខាងការទិតបានធ្លាក់ទៅនៅក្នុងអំណាចរបស់ពួកបាលវៈ ដូចបានពោលពីខាងដើមរួចមកហើយ ។ ពួកបាលវៈបានគ្រប់គ្រងខែត្រការទំគជាវេលាពេង ២០០ ឆ្នាំ ហើយបានផ្សាយអំណាចចេញទៅខាងជើងរលំទន្លេគោធាវរី ហើយភាគខាងរហូតដល់មទ្រាស គឺថាអំណាចរបស់ពួកបាលវៈផ្សាយចេញទៅក្នុងភាគធំក្នុងដែនតេលុគុ ទើបពួកទមិឡត្រូវអំណាចរបស់ពួកបាលវៈសង្កត់សង្កិនជាខ្លាំង លុះដល់សម័យពួកបាលវៈអស់អំណាចហើយ ទើបពួកទមិឡមានឥស្សរៈឡើងវិញ ។ តាមដោយពិតនោះ ពួកដែលលុបលាងអំណាចរបស់ពួកបាលវៈនោះ មិនមែនជាពួកទមិឡទេ គឺពួកក្សត្រវង្សចាលុក្យៈនៃដែនមហារាស្ត្រ ដែលបានលុបលាងអំណាចរបស់ពួកទមិឡ ទើបជាហេតុឲ្យពួកទមិឡរួចរបូតអំពីអំណាចរបស់ពួកបាលវៈ ហើយតាំងវង្សគោលៈឡើង មានព្រះចៅផែនដីអង្គដំបូង ១ អង្គ ព្រះនាមថា បរន្តកៈ

បាន[គប់[គងពួកទមិឡជាវេលា ៤១ ឆ្នាំ គឺតាំងអំពីពុទ្ធសករាជ ១៤៥០ ដល់ពុទ្ធសករាជ ១៤៩០ [ទង់បានព[ងីកអាណាខេ[ត[គប់[គងដែន បាលវ: បានទាំងអស់ ហើយមានកំឡាំងអំណាចឡើង[ចើន ឆ្លាប់ លើកទ័ពឆ្លងសមុ[ទទៅវាយដល់កោះលង្កា កាលពីពុទ្ធសករាជ១៤៨៦ ។ តែវង្ស[ក្ស[តខាងមហាព[ស្ត្រដែលបានបំផ្លាញអំណាចរបស់ពួកបាលវ: នោះ ក៏មានបំណងនឹងចូលទៅ[គប់[គងដែនបាលវ: លុះបានឃើញ វង្ស[ក្ស[តតាំងឡើងថ្មីរបស់ពួកបាលវ: ហើយមានកំឡាំងខ្លាំងពូកែដល់ ម្ល៉ោះ ក៏មិនអាចនឹងសម្ងំនៅស្ងៀមបាន ក្នុងពុទ្ធសករាជ ១៤៩២ [ពះចៅ ផែនដីមហារា[ស្ត្រ ១ អង្គ [ពះនាម[គិស្ណរាជទី ៣ នៃរាជវង្សរា[ស្ត្រកូត ចូល ទៅវាយ[សុកការន៍ត ទើបអាណាច[កគោលៈក៏ចុះខ្សោយចុះអំណាច អប្បពន្ធីរស៊ី ក្នុងរវាងវេលា ២៥ ឆ្នាំ ទើបមានអំណាចរុងរឿងឡើងវិញ ទៀត ហើយនៅ[គានេះ [តទរបជាមានកំឡាំងរឹងប៉ឹងខ្លាំងពូកែជាង មុនទៅទៀត ដោយមាន[ពះចៅផែនដីដែលខ្លាំងពូកែ ១ អង្គ [ទង់[ពះ នាមរាជៈរាជ [ទង់[គប[គងខេ[តការន៍តជាវេលា ២៥ ឆ្នាំ គឺ តាំងអំពីពុទ្ធសករាជ ១៥២៨ ដល់ពុទ្ធសករាជ ១៥៥៤ [ពះចៅផែនដី អង្គនេះ បានធ្វើឲ្យពួកទមិឡមានអំណាចយ៉ាងធំ[ករៃលងឡើងក្នុងខេ[ត ដិកក័ន បានទាំងរូបរួមខេ[តដិតខាងចូលមកនៅ[កោមអំណាចរបស់[ទង់ ផង ហើយថែមទាំងបានវាយយកដែនពួកមីសូរបាន ១ ចំណែកទៀត

ផង ទើបកើតជាគ្រូបណ្តាំប្រដែងគ្នាដ៏សំខាន់ ទីង្រ្រះចៅផែនដីខាង មហាក្សត្រ ។ ព្រះបាទពជៈរាជអង្គនេះ ធ្លាប់លើកទ័ពទៅលុកលុយរហូតដល់កោះលង្កាផង ។ ទីក្រុងរបស់ព្រះមហាក្សត្រអង្គនេះ ហៅថា តន្ទូរ ទ្រង់បានរៀបចំកសាងទីក្រុងនេះឲ្យបានល្អរុងរឿង ហើយទ្រង់បានវត្តមួយហៅថា វត្តតន្ទូរ ជាគ្រឿងសំដែងថ្វីដៃខាងសិល្បកម្មយ៉ាងឯករបស់មីលក្ខៈ ។

អាណាចក្រគោលៈបានចំរើនរុងរឿងឡើង ហើយមានអំណាចខ្ពង់ខ្ពស់បំផុតក្នុងសម័យព្រះបាទរាជេន្ទ្រ គោលៈ ទេវៈ ដែលគ្រង់រាជសម្បត្តិជាវេលា ៤២ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១៥៥៤ ដល់ពុទ្ធសករាជ ១៥៩៥ ព្រះចៅផែនដីទ្រង់ពង្រីកអាណាខែត្ររហូតដល់បេង្គាល ហើយរាតតមកទៀតរហូតដល់ប្រទេសភូមា កងទ័ពជើងទឹករបស់ព្រះអង្គក៏បានធ្វើជានាយៈចាហ្វាយលើឈូងសមុទ្របេង្គាល មានអំណាចតាំងអំពីកោះលង្ការហូតទៅដល់ច្រកកោះមលូកា ។ អារ្យធម៌របស់ពួកទមិឡក៏បានផ្សាយរីកពាយចេញទៅដល់ប្រទេសជ្វា រហូតមកដល់ស្រុកខ្មែរយើងនេះផង ។

អាណាចក្រទមិឡជាតិដ៏ចំរើនឡើងត្រឹមណា អាណាចក្រមហាពក្សត្រក៏មានតែឈឺចាប់ខ្លោចផ្សា ប្រើនឡើងត្រឹមនោះដែរ ព្រោះរាជាកំហុសរបស់ខ្លួនដែលបានទៅប្រាបប្រាមពួកបាលវៈជាហេតុធ្វើឲ្យពួកទមិឡ

មានកម្លាំងរឹងប៉ឹងខ្លាំងពូកែឡើង តែព្រះចៅផែនដីមហាក្សត្រមិនមានព្រះទ័យរួញរា នឹងការប្រណាំងប្រជែងអំណាចគ្នានឹងអាណាចក្រទមិឡ ក្នុងរវាងពុទ្ធសករាជ ១៦០០ ទើបក្សត្រមហាក្សត្របានខំប្រឹងព្យាយាមក្នុងការធ្វើជាមហាអំណាចក្នុងខែត្រជិតក័នហើយ ទើបទ្រង់ប្រកាសសង្គ្រាមលុកចូលមកមួយលើកទៀត ក្នុងពុទ្ធសករាជ ១៦០២ ព្រះបាទរាជៈរាជរបស់ពួកទមិឡក្សយព្រះជន្មក្នុងសមរភូមិ ។ ការបរាជ័យគ្រានេះ ជាគ្រឿងសំគាល់នៃសេចក្ដីវិនាសនៃរាជវង្សគោលៈ របស់ពួកទមិឡ ព្រោះតមកទៀត ១១ ឆ្នាំ ក្នុងពុទ្ធសករាជ ១៦១៣ រាជវង្សគោលៈរបស់ពួកទមិឡក៏ផុតអំណាច ហើយវង្សក្សត្រដែលគ្រប់គ្រងស្រុកវេង្គី ទ្រង់ព្រះនាមរាជេន្ទ្រៈគោលៈទេវៈទី ២ ជាក្សត្រដែលតមកពីព្រះវង្សក្សត្រគាលុក្យៈរបស់មហាក្សត្រ បានចាប់តាំងវង្សឡើងថ្មីហៅថាវង្សគោលៈគាលុក្យៈ ។ កាលអាណាចក្រទមិឡបានផ្លាស់នាយចៅហ្វាយដូច្នេះហើយ ក៏គាន់តែមានសេចក្ដីចំរើនរុងរឿងឡើងជាអនេក ។ គឺមានអំណាចគ្រប់គ្រងរហូតទៅដល់មាត់ទន្លេគោធាវរី ហើយមានសេចក្ដីចំរើនឡើងតទៅទៀតជាច្រើន ។ តែនៅទីបំផុតអាណាចក្រគោលៈ ដែលមានឈ្មោះហៅម្យ៉ាងទៀតថា មហាអាណាចក្រទមិឡខាងការន័ត ក៏សាបសូន្យអំណាចចុះទៅ ហើយមានពួកជនដែលខ្លាំងពូកែ ១ ពួកទៀត ឡើងមកជំនួសជនពួកនេះហៅថា រាវសមុទ្រ ឬហៅថា មីសូរ ។

បានពោលពីខាងដើមរួចមកហើយថា ប្រទេសមីស៊ួរជាទីទួលខ្ពស់ ហើយមានផ្ទៃដីរាប ៗ ខ្ពស់ ៗ នៅចន្លោះនៃត្រការទេតទឹងមាណបារ៍ ជនជាតិជាម្ចាស់ដែនដីនេះជាពូជពួកគេលុគុលាយគ្នានឹងពួកទមិឡ ដែនមីស៊ួរចាប់ផ្តើមមានកេរ្តិ៍ឈ្មោះល្បីក្នុងប្រវត្តិសាស្ត្រឡើង កាលរវាងពុទ្ធសករាជ ១៧០០ មានវង្សក្សត្រខ្លាំងពូកែដែលហៅថា វង្សហ្វូយសាក បានចាត់តាំងអាណាចក្រឡើងហៅថា ទោរៈសមុទ្រឬទ្វារសមុទ្រ មីស៊ួរ មានទីក្រុងហៅថា ស្រុកហាលេប៊ិត ព្រះចៅផែនដីអង្គដំបូងព្រះនាមថា ព្រះបាទវិស្ណុវី ១ ទ្រង់ឡើងគ្រប់គ្រងអាណាចក្រទោរសមុទ្រ កាលពីពុទ្ធសករាជ ១៦៦០ ជាពួកដែលកាន់សាសនាដៃនិស៊ុ ទ្រង់ធ្វើចម្បាំងឈ្នះក្សត្រគោលៈ ធ្វើឲ្យប្រទេសរបស់ព្រះអង្គផុតរបូតពីអំណាចរបស់ទមិឡ ហើយជាហេតុនាំឲ្យពួកមីស៊ួរចំរើនរុងរឿងឡើងដូចជាពួកទមិឡដែរ តែគោងធ្វើចម្បាំងតទល់នឹងពួកមហាក្រស្ត ឯពួកមហាក្រស្តនឹងពួកមីស៊ួរនេះបានច្បាំងតស៊ូគ្នាជាវេលាយូរ ត្រាតែទាំង ២ ពួកមានកំឡាំងទន់ខ្សោយចុះទៅតមកដល់ពុទ្ធសករាជ ១៨៥៣ ទើបត្រូវពួកអ៊ីស្លាមវាយយកដែនមហាក្រស្ត ហើយវាយបានដែនមីស៊ួរឬទោរសមុទ្រថែមទៀតផង ។

នៅមានអាណាចក្រ ១ ទៀត ដែលតាំងខ្លួននៅបានយូរអង្វែងហៅថា អាណាចក្រទ្វារង្គាលឬវារង្គាល តាំងនៅក្នុងខេត្តដែនតេលុគុ តែច្រើនហៅថាអាណាចក្រតេលង្គណៈ នៅកណ្តាលខេត្តដិកកន គឺត្រង់

កណ្តាលទន្លេគោធាវរីនិងទន្លេក្រិស្ណា ។ អាណាចក្រនេះ បានចំរើន តស៊ូទប់ទល់ពួកមហាហ្ម័តជាវេលាយូរណាស់ តែនៅទីបំផុត ក៏ធ្លាក់ ទៅនៅក្នុងអំណាចរបស់ពួកមហាហ្ម័តកាលពីពុទ្ធសករាជ ១៩៦៧ ។

ក្នុងខណៈដែលអាណាចក្រកណ៌ាតទាំងឡាយ រៀវរោយចុះទៅ ក្នុងសម័យកណ្តាល នៅមានអាណាចក្រមួយ គឺវិជយនគរ ដែលបាន រក្សាឥស្សរភាពនៅបានជាវេលាយូរដល់ ២ សតវត្សរ៍ ទើបតែនឹងធ្លាក់ ទៅនៅក្រោមអំណាចរបស់ពួកអ៊ីស្លាម កាលពីពុទ្ធសករាជ ២១០៩ ។

នៅវេលាដែលពួកអ៊ីស្លាមលុកលុយចូលមកក្នុងដែនវរង្គាល ជា គ្រាដំបូងនោះ មានព្រះអង្គម្ចាស់តេលុគុ ២ អង្គបងប្អូន ព្រះនាមថា ហរិហរ ១ អង្គ ពុក្ករ៉ា ១ អង្គ បានគេចាប់ចូលមកពួននៅទីនាប តុង្គកទ្រៈ ខាងប្រទល់ស្រុកម៉ុស្លុំ ។ នៅទីនោះ ក្សត្រហរិហរទ្រង់ កសាងអាណាចក្រ វិជយនគរឬដែលហៅថា ពិសនគរ កាលពីពុទ្ធ-សករាជ ១៨៧៨ នគរនោះចំរើនក្រៃណាស់ ដែលមិនត្រូវពួកអ៊ីស្លាមចូល ទៅលុកលុយញាំញីតាំងពីដំបូងដៃ ។ ក្សត្រហរិហរបានគ្រប់គ្រងមាន សេចក្តីចំរើនរុងរឿងរហូតមកដល់ពុទ្ធសករាជ ១៨៨៦ ក៏ក្ស័យព្រះជន្មទៅ ហើយក្សត្រពុក្ករ៉ាជាព្រះអនុជាគ្រប់គ្រងតមកទៀតរហូតដល់ពុទ្ធសក-រាជ ១៩២២ បានផ្សាយអំណាចរហូតដល់ទន្លេក្រិស្ណានិងគោធាវរី បាន ខេត្តដែនមីសូរទាំងមូល និងខេត្តដែនការនាតខាងជើងផង ។ ក្សត្រ ដែលគ្រងរាជ្យតពីក្សត្រពីរអង្គនោះមក បានគ្រប់គ្រងខេត្តដែន (មានត)

# រឿងភោគកុលកុមារ

អ្នកឧកញ៉ាព្រះឃ្លាំង នង រៀបរៀង

(តមក)

---

**ច៩ ភាគទី**

កាលណោះព្រះអង្គ អំបូរពូជពង្ស សារពេជ្រប្រាស់ប្រួង ស្ដាប់ពាក្យសេនា យោធាពលផង អញ្ជើញទៅគ្រង ពស្ដ្រពជរដ្ឋា ។ ស្ដេចព្រមព្រះទ័យ ទើបក្សត្រជេស្ឋជ័យ ទូន្មានជាយា បែរបើកបន្ទូល មធុរត្រាស់ថា ហៃអស់អង្គអា - មាត្យមុខមន្ត្រី ។ បើអស់គ្រប់គ្នា ចង់ឲ្យយើងជា ក្សត្រាធិបតី ចូរសង់មន្ទីរ ជាកើ្ដរថ្មោងថ្មី យើងពុំនៅទី ដែលស្ដេចព្រហ្មទត្ត ។ មើលបានទទួល ឯណាសមគួរ សមជាទីក្សត្រ រិះគិតស្រួលរៀប រណ្ដាប់ថ្វាត់ៗ គាត់តែងចាប់ចាត់ បែងចែកដោយការ ។ ធ្វើឲ្យសមគួរ ហើយមកទទួល អញ្ញទឹងការិយា មន្ត្រីផងស្ដាប់ បង្គាប់ក្សត្រា ទើបតែងដោយការ ដោយមុខទីទៃ ។ ខ្វះក្រាបលុតលា បេញបម្រើម្មា រើសរកឈើព្រៃ ខ្វះដេកចាំនៅ គាល់ហ្វាក្សត្រថ្ងៃ គ្រៀងគ្រប់ដោយដៃ ចាំក្សត្រពីរពង្ស ។ ខ្វះដើររកមើល ទីភូមិសារសើរ គួរជាស្ដេចគង់ យល់ទីមួយធំ សួស្ដីសមគួរសង់ មន្ទីរទើបទង់ ខ្សែសិណបុះបោះ ។ រាស់ចែកដោយការ កំណាន់ខ្នាន់ការ គតឯបន្ទោះ ប៉ុកចាំងព្រាលប្រាស់ ឲ្យពបស្មើស្មោះ

លុះល្ងាចរំលងផ្ដោះ ទៅផ្ទះទីទៃ ៗ ហេតុតែសម្ភារ ពង្សព្រាជសារ-
តេជពុទ្ធញ្ញាណព្រាយ ក្ដៅដល់អាសនា ឥន្ទ្រាចាំថ្ងៃ ដូចភ្លើងវិស័យ
ពេលកលមហិមា ៗ ព្រះឥន្ទ្រប្រែក្រ្ត បែរបើកទិព្វចក្ខុ សហស្ស
នេត្រា ទតយល់ព្រះអង្គ ពូជពង្សស្រាស្ត្រា ខ្ញុំនាងសុខុមា - លក្ខា-
ទេវី ៗ បរិបូណ៌បានជា ស្ដេចស្ដែងនៅនា ពារាណសី ពុំមានមន្ទីរ
ជាគ្រឿងបានថ្មី សមគួរជាទី លំនៅក្សត្រា ៗ ទៀងទើបព្រះឥន្ទ្រ
ចមបោះទេវិន្ទ្រ បរមទេពា មានព្រះបន្ទូល មធុរត្រាស់ថា ហៃពិស្ណុការ
បាចូរចុះទៅ ៗ សាងសង់ប្រាសាទ ទាំង ៥ ស្អាងស្អាត សឹងមាស
សន្ធៅ ដាំដាសកយរត្ន ចាយក្សត្រចមបៅ ទាំងពីរទិត្យនៅ ពារាណ-
សី ៗ កក្កុកំពែង កែវគិតគាក់តែង ឲ្យសមសោភ័ ឲ្យបានរួចក្នុង
កម្ពង់ពត្រី យប់នេះកុំបី ធ្យន្ធ្យរេភ ៗ ព្រះពិស្ណុការស្ដាប់ ទទួល
បង្គាប់ សម្ដេចឥន្ទ្រា ក្រញូងក្រាបប្រណម្យ បង្គំលុតលា នាំអស់ទេវតា
ទេវបុត្រច្រើនក្រៃ ៗ ហោះចុះមកត្រង់ ទីភូមិនឹងសង់ មន្ទីរក្សត្រថ្ងៃ
គន់គិតធ្វើជា ប្រាង្គប្រាសាទជ័យ ទាំង ៥ ត្រៃលៃ ត្រឈឹងខ្ពស់ខ្ពង់ ៗ
សឹងមាសចំណាច ចំពោងត្រដាប ត្រៃដេតដោមដុង ដាំដាក់រត្នពយ
ឆាឆាយយល់យង់ គាងឃ្វាយចមចុង កែវកែមរចនា ៗ ស័ក្តិសម
កំពូល កំពស់ត្រីសូល ជង់ក្ដារជហ្វា មុខនាគផ្ទាក់ឈ្លូប រំលេចរចនា
កែមកែវមុក្ដា មរកតកាលកិត ៗ រនូតរនាំង រនាបជញ្ជាំង ចំពោច.

កាយរត្ន រៀបរៀងរំលេច ដោយក្បាច់ដាំលដិត ផាសដេរប្រកិត ប្រ-
កបស័ក្តិសម ៗ ហោជាំងក្បូរក្បាច់ ឆ្លាក់ឆ្មៅឆ្លូកឈ្លូច ជាទេព
ប្រណម្យ កាន់ភ្នីវល្លិពង់ ពាក់ព័ន្ធភ្លៀងភ្ញុំ ក្លែងក្លាយបន្ទុំ ជារូប
ពានរ ៗ ប្រែប្រឹងប្រាណប្រញ កាងកកន្ត្រញ កាន់ភ្នីឈានឈរ
ក្លាយជានរសីហ៍ ដំរីនាគនរ ក្លាយជាកិន្នរ រកាំកាន់ភ្ញី ៗ កញ្ចាំង
ខែនខយ សារពយកករយ រៀបរាយមណី រត្នរៀងរំលេច ដោយក្បាច់
រសកត៍ ឆ្លាក់ឆ្លុះស្មើ ភ្លឺឆ្លុករព្រោងព្រាយ ៗ សសរស្តម្ភស្តែង សឹង
មាសខមេ្ទង ល្អល្អះពណ៌រាយ ស្លាមស្លឹកខ្នុរខ្នាប់ ប្រដាប់ភ្លៀមក្លាយ
ជាភាពរៀងរាយ ត្របកបវុមា ៗ ងាសងាំរំលេច សឹងស្បូវកាន់ពេជ្រ
កែមកែវមុក្តា ពពាលរត្នរាយ ពិទាយភាព នែបតៃទូវ្យទា - ទិម ៗ
ស្រស់ស្រី ៗ ឆ្លុកឆ្លាស់មារកដ កែមកែវបុស្សរត្ន តៃទូវ្យជាំតិត្រ
ខុមពគទឹករំល ពព្រិលរស្មី នៃបនៅមណី រត្នរាយរោទ ៗ ក្រឡាបន្ទំ
ខែនទិព្វឧត្តម សឹងរូបយក្ស កុម្ភណ្ឌគ្រុឌគ្រប់ ស្អាញស្អប់បុរាទា កែ
កាងហត្ថា ប្រែប្រឹងទ្រាទ្រ ៗ ឈ្លុកឆ្លាប់ក្បាច់ពេជ្រ ល្អសលាយ
រំលេច ទងទាក់ទៅមក ជាភ្ញីពេនពាក់ ឆ្លាយឆ្លាក់ល្អះល្អ ក្លែបក្លាយ
ជាជរ កិតានសំយុង ៗ ក្រឡាទីនាំង កុះករល់បល្ល័ង្ក ពានរទ្រទ្រង់
ត្របកឈ្លុកឆ្លាក់ ជាំជាក់រត្នរង - រឿងរំលេចក្នុង ចម្លាក់ព្រោងព្រាយ ៗ
មានស្មូតប័ត្រ ប្រាំពីររត្នរត្ន បើកបាំងរៀងរាយ គប់គ្រែមាសមាន

ពិតានរំកាយ រំភើយត្រសាយ ត្រសាក់ស្ពស្ព័សម ៗ កន្ទ្រាមត្បារផ្កា សំយុងមាលា រំយោលផិតផ្ទុំ ខ្នើយខ្នល់ព្រះក្រាល កម្រាលជៀមចំ ពូកពាសព្រែព្រំ ប៉ុកប៉ុនសុវណ្ណា ៗ វៃផ្សផ្សំកេងកន កេងរម្យសោត មាន កេងយាមនាឡិកា កេងដាក់ដំរី កេងពាជីរថា សាល័យសាលា បញ្ចាន់សឹងសម ៗ មានផ្ទះមណ្ឌប ពិសេសគ្រគប់ កនហាលជេងធំ កំផែងខាងកំផែងខ័ណ្ឌ ច្រើនជាន់ផិតផ្ទុំ ផ្ទះស្រីព្រះស្នំ រៀបរៀងកល់កយ ៗ កំពែងកែវកិត ប្រាំពីរជាន់ជិត ផ្ទុំជាបន្ទាយ ទល្ហនាងប្រាល រន្ទាល ពព្រាយ ពព្រោងក្លីសាយ ក្លីសព្វទិសា ៗ មានទាំងមណ្ឌប ដាក់ ដោយទ្វារគ្រប់ មុំមានបញ្ចា ដោយមុំខាំងខ័ណ្ឌ មានចន្ទួធាយា មាន ស្រះស្រង់ថ្លា សម្រាប់ក្សត្រថ្ងៃ ៗ ឃ្លាំងមាសឃ្លាំងប្រាក់ ឃ្លាំងព្រែ សុភ័ក្ត កាសាកោសេយ្យ ពស្ត្រាទិព្វទេស ពិសេសច្រើនក្រៃ ពេញ ទាំងឃ្លាំងជ័យ ឥតឯគណនា ៗ ព្រះពិស្ណុការ ជាងចេះរចនា គាក់ តែងប្រាក្ដប្រា - សាទដូចឋាហាន ពិមានសួគ៌ា ស្រូតស្រុឧមកនា ភូមិ ភពផែនដី ៗ សរសេរអក្ខរ នៅក្លោងទ្វារចា សម្ដេចកោសីយ៍ ប្រើ ពិស្ណុការ សម្មាមកពី សួគ៌ាស្ថានទិព្វទី ប្រាសាទសុវណ្ណា ៗ ថ្វាយ ក្សត្រពីរពង្ស អញ្ជើញស្ដេចគង់ ក្រមក្សាន្ដចិន្តា ហើយហោះវិលវង់ ត្រៃត្រឹង្សសួគ៌ា ទូលព្រះឥន្ទ្រា សុះសព្វសេចក្ដី ៗ លុះព្រឹកស្រាង ស្រេច សូរ្យសែងឡើងលេច ពីបូព៌ទិសទី អស់អគ្គសេនា យោធាមន្ត្រី

ភ្ញាក់ភ្ញាក់ឡើងពី ដំណេកនិទ្រា ៗ រលះរលាំង លុបលាងមុខទាំង
ខ្ពុរមាត់ចំទំស្លា ហើយហៅកូនក្មួយ តាមក្រោយយាត្រា ចេញចាក
គ្រឹះហា ទៅធ្វើរាជការ ៗ មៀងមើលទៅត្រង់ ទីដែលទឹងសង់
មន្ទីរក្សុបាល យល់ប្រាសាទមាស ឧភាសរន្ទាល បញ្ជរច្រើនប្រាល
កែមកែវព្រោងព្រាយ ៗ កាន់កាំងផ្អុកស្អិល ហៅគ្នាមៀងមើល
អំពីចម្ងាយ ថារុយគ្នាយើង ធាប់ឡើងមកអាយ មើលទៅឯនាយ
ភ្លឺភ្លឺដល់ម៉េះ ៗ ចៅខ្ទុះធ្លាស់ធ្លើយ ភ្លើងឆេះឈើហើយ ទើបភ្លឺដូច្នេះ
នាយដេរទៅថា ម្ដាយអាស្លាប់បែះ ភ្លើងអ្វីទ្វារឆេះ ភ្លឺធ្លេកត្រកាល ៗ
កូនក្មួយខ្ទុះធ្លើយ ទៅថាលោកអើយ ភ្លឺដូចមេឃដាល ដុំៗដូចផ្កាយ
ព្រោងព្រាយរន្ទាល អស្ចារ្យត្រកាល ចំឡែកមហិមា ៗ នាយជា
អាមាត្យ មើលហាក់ប្រាសាទ ប្រសើរម៉េនថា ជុំវិញតូចៗ ហាក់ដូច
បញ្ជា អាតាមតែបា ពព្លើពព្លាក់ ៗ សង្ឃឹមក្អែកអា ឲ្យមើលគ្រប់គ្នា
ដូចប្រែមនុស្សភ្ញាក់ ចាញ់ទឹងក្អែកចាស់ ឆ្ងាយណាស់ដៀងជាក់ អញ
មើលយល់ហាក់ ប្រាសាទសុវណ្ណា ៗ មន្ត្រីតូចធំ រូតរត់បំព្រំ បំព្រោង
គ្រប់គ្នា បែកញើសហូរហូត រន្ធត់គ្រប់គ្នា ដល់មុខនាគនា ក្បោង
ទ្វារកំពែង ៗ មើលយល់អក្ខរ សរសេរទុកថា គឺព្រះឥន្ទ្រឯង ប្រែ
ពិស្ណុកា សម្មាតាក់តែង ធ្វើថ្វាយស្ដេចស្ដែង គួរគង់ក្សេមក្សាន្ត ៗ
មន្ត្រីទាំងឡាយ អរឯងកែកពយ ពេកពន់ប្រមាណ សឹងសរសើរថា

ចាំនុបុរាណ សំណាងយើងបាន ម្ចាស់ថ្លៃមានបុណ្យ ៗ ពីដូនពីតា
ពីទូតល្អតលា រៀងរាល់ពីមុន គតអង្គក្សត្រា ឯណាមានបុណ្យ យើង
មានភ័ព្វពាន់ ភ័ព្វតេជមហិមា ៗ បានចួបនឹងម្ចាស់ មានបុណ្យក្រៃ
ក្រាស់ គតឯគណនា យើងទទឹងបានសុខ នៅមុខគ្រប់គ្នា ដោយបារមី
មហា - ក្សត្រថ្លៃថ្កើងថ្កាន ៗ គតទុក្ខគតភ័យ គតស្តេចដទៃ ណាមក
បៀតបាន ទើបនាំគ្នាដើរ ចូលមើលសព្វឋាន ប្រាសាទមាសមាន
វិចិត្រខ្លាត់ខ្លួន ៗ យ៉ាំងប្រាក់យ៉ាំងមាស យ៉ាំងសំពត់ពាស ពោរ
ពេញគ្រប់ល្វែង ត្រិប្រុងពេមា គ្រប់គ្នាស្ញប់ស្ញែង កោតបេស្ដាស្ដែង
លើសលើលោកា ៗ មន្ត្រីអង្គអរ នាំគ្នាចេញចរ ទៅទីសាលា ខ្លះរត់
ផ្ដោះទៅ លំនៅក្សត្រា ទូលព្រះពណ៌ ឲ្យប្រាប្រជាមុន ៗ ខ្លះទៅ
ប្រដាប់ ដង្ហែប្រាមប្រាប់ ការស្ដែប្រជាជន ចាមចិនកួយគាំង ជ្វារាំង
ជប៉ុន យួនលាវសៀមល - ង្វាទាំងភូមា ៗ ក៏កាន់លំពែង ដាវខ្វែ
ដាវវែង កាំភ្លើងធ្នូស្នា ក្បួនក្រោមត្រីត្រែ ដង្ហែក្សត្រា ភ្លេងចិនភ្លេងជ្វា
ភ្លេងសៀមមហោរី ៗ ទាំនាំងគងសា បង់គ្រឿងរបនា សឹងមាស
មណី គេដន្រ្ទប្រាសាទ ព្រោងព្រាតរស្មី ស្វាប់មុខសោភី ទង្កន់ខ្សែ
ផ្ទាក់ ៗ ភ្ញាក់ស័ក្តិសម សុទ្ធសឹងបន្ក មាសមានបម្លាក់ បម្រែកល្អ
ល្អះ ដងក្រពាត់ពាក់ ខ្សែយោងប្រាក់ ប្រក់រង្សី ៗ ទាំនាំងអស្ស-
ពាហណ៍ ភានមាសមុខក រុងរឿងរស្មី ខ្សែហាងក្បូបចាំង បុស្បនាំង

ចោនទ្ទ ឃ្មុំមុខមណី កែមកែវយល់យន់ ៗ តែអុកតែថោង ខ្សែ
ហាងខ្សែហោង ដោតដាក់ប្រន្ទន់ បង្កាប៉េកប៉ាក់ ដាំដាក់ត្បូងផ្លូង ខ្សែ
ឈ្នាន់សំយុង សំយ៉ាកឆេតឆាយ ៗ ទីនាំងកជរថ ទីមរសេះសស្ទុ
តីរ៉េណ៍ពណ្ណរាយ ទ្រពាំងទ្រៀរឆ្នួង កាំកង់ព្រែកព្រោយ ដាក់ដាំរត្ន
រាយ រំលេចរចនា ៗ ផងខ្លោលសឹងពេជ្រ ធ្លាក់ផ្ទៀរំលេច ជាត្បូងទា-
គា ខ្សែនាមខ្សែបរ បរិសោភា ល្អសមាសបាក់ជា ក្រញ៉ូលសាក់
ស្រម ៗ ប្រដាប់គ្រែព្រះ រាជយានល្អល្អះ សឹងមាសឧត្តម ចាម
រប៉ាយមន់ សែនត្បាន់កូស៊ក្កុ សែងស្បូវអភិរម្យ រៀបរៀងត្រៀបត្រា ៗ
អស់អគ្គខុនណាង តែងត្លុស្អិតស្អាង ប្រដាប់អាត្មា សឹងឡើងជាន់ជិះ
រទេះនោងជា ទៅទទួលមហា - ក្សត្រថ្ងៃតីរពង្ស ៗ អស់មុខមន្ត្រី
សឹងជិះពាជី ប្រដាប់អស់អគ្គ នាំគ្នាដង្ហែ បរបែរដម្រង់ ទៅទីស្តេចគង់
និត្យនៅចម្ការ ៗ ដល់ស្រែបទុនអគ្គ ក្រួញក្រោបជួញជង្ស ប្រណម្យ
ទូលថា បពិត្រព្រះអគ្គ ទ្រើសទ្រង់ចេស្តា យើងខ្ញុំគ្រប់គ្នា ដើរទៅមៀង
មើល ៗ យល់ភូមិមួយម - ង្គលគាប់គួរសង់ មន្ទីរប្រសើរ ចូកចាំង
ប្រាសប្រាប់ ឲ្យរាបបណ្តើរ ដល់ល្ងាចយប់ស្មើរ រិលមកនិទ្រា ៗ
លុះព្រឹកឡើងវិញ នាំគ្នាចរចេញ ទៅទីត្រិហា យល់ប្រាសាទមាស
ធ្ងុះធ្លាសនៅនា ភូមិទីងសង់ជា មន្ទីរក្សត្រថ្ងៃ ៗ មានត្លុកំពែង កែវ
កើតខ្វាត់ខ្វែង ព្រោងព្រាយប្រពៃ អស្ចារ្យបំខ្សែក ពន់ពេកល្អក្រៃ យើង

ខ្ញុំទទៃ ស្រែតដំរង់ ៗ ដល់យល់អគ្គ នៅភ្នាក់ទ្វារថា ព្រះតម្រៀ
ទ្រង់ ប្រើព្រះពិស្ណុការ សម្មាមកសង់ ធ្វើថ្វាយព្រះអគ្គ អម្ចាស់មាន
បុណ្យ ៗ យើងខ្ញុំចូលមើល ក្នុងបានប្រសើរ ប្រាសាទទិព្វគន់ មាស
អើយអម្ចាស់ ល្អណាស់ពេកពន់ មានឃ្លាំងទ្រព្យធន ដូចឋានសួគ៌ ៗ
ឥឡូវយើងខ្ញុំ ចូលមកសូមសុំ អញ្ជើញក្សត្រា ក្សត្រីបវរ ទៅគង់
ប្រាង្គណ៍ប្រា - សាទសោយពន្សា ឥសូរសិរសី ៗ កាលណោះ
ព្រះអគ្គ ក្សត្រទាំងពីរពង្ស ស្តាប់ពាក្យមន្ត្រី ក្រាបទូលគ្រាន់គ្រប់ ស៊ុះ
សព្វសេចក្តី ទ្រង់ព្រះបេតី ត្រេកសោមនស្សា ៗ ក្សិណក្សត្រវរវង្ស
ទាំងពីរស្តេចទ្រង់ គ្រប់គ្រឿងរចនា មកុដកែវកង អម្ពរពស្ត្រា
សង្វារមាលា អាភរណ៍រត្នភាយ ៗ ទើបមហាក្សត្រក្សាន្ត ឡើងគង់រាជ
យាន មាសវៃចេតឆាយ បើកចាំងអត់ម្យ ក្ងស់ក្ងម៉ាយ រំភើយត្រែ
សាយ ត្រសៀកពាត ៗ រាជក្សត្រី ឡើងគង់ដំរី ទីនាំងសោភា
អករយាយខុនណាង ហែខាង: គៀបត្រា ស៊ីងជិះថា បរក្រោយរៀង
ពយ ៗ តូរ្យតន្ត្រីត្រែ - ស័ង្ខសព្ទស៊ានសែ ព្រលេចស្ងូរសាយ ស្គរ
ទ័ពស្គរផ្ទា ស្គរឆាវកែកាយ គងគរលំពយ ដោយឆាវទទៃ ៗ អស់
មុខមន្ត្រី ក៏កាន់ឆាវខ្ញី - ដើរហែក្សត្រថ្វៃ ធ្វេងស្តាំបង្ហ ក្រោយក្រែល
ក្រាសក្រែ គ្រឿងគ្រប់ដោយដៃ ប្រឹនប្រុះប្រុងប្រាង ៗ ភ្លេងចិន
ភ្លេងផ្ទា ភ្លេងសៀមរាមនា ដើរដោយសងខាង ជាផ្លូវសង្កាត់ ហែ

ក្សត្រនូវនាង ទៅគាល់ទីប្រាង្គណ៍ ប្រាសាទសោភី ៗ ស្តេចនាំក្សត្រី
ប្រទក្សិណបី ជុំវេលា ទតទីពិមាន ហាក់បានសួគ៌ា ពេញព្រះ
ទ័យា សោមនស្សប្រតី ៗ ទតស្រេចព្រះអង្គ លីលាឡើងគង់ ប្រាង្គណ៍
ប្រាសាទស្រី អគ្គយាយចាស់ទុំ ស្នំស្នំនារី សេនាមន្ត្រី គង់
គាល់ត្រៀបត្រា ៗ ទើបមន្ត្រីធំ រំពឹតជំនុំ គាក់តែងអាជ្ញា ស្រុក
រូតចេញទៅ ស្រុកក្រៅនានា ប្រាមប្រាប់ប្រជា - រាស្ត្រផងសព្វសាយ
ប្រាប់តាមភោជក ជាទៅមឿងស្រុក គប់ខែត្រទៀបឆ្ងាយ រកបណ្ណា
ការ ក៏ស្តុការជន្លាយ នាំចូលមកថ្វាយ បង្គំក្សត្រថ្មី ៗ ទើបឲ្យបុរោ
ហិត អាចារ្យព្រាហ្មណ៍ព្រឹទ្ធ ហោរាសាស្ត្រសេយ្យ គន់គូរឫកបារ
ភេការប្រពៃ មានឫក្សជោគជ័យ ឧត្តមវេលា ៗ នឹងរៀបអភិសេក
ព្រះពោធិឯក នូវនាងជាយា ទាំងពីរព្រះអង្គ ទើសទ្រង់រាជា តស្សូរ
រង្គា វេជ្ជជាន ៗ ប្រុងប្រៀបប្រដាប់ គាក់តែងបង្គាប់ អស់មុខ
មន្ត្រី ខុនណាងតូចធំ ជ្រើសចំណី បន្ថែមពិសី ពិសាត្រកាល ៗ ចំ
ណីចំអាប ខ្លួស្ងួជកប គប់ពណ៌ភោជន៍ការ ចំណីចិនជ្វា កូមាសៀម
លាវ ផ្ទៃភោជន៍អាហារ មិនឲ្យមានខ្វះ ៗ រើសកូនមន្ត្រី សេនា
សេនី រូបកង់ល្អល្អះ កក្រាផ្លូវផង់ ត្រង់ត្រះ ទៀបដើរហែព្រះ
មហាក្សត្រទាំងទ្វី ៗ ពាក់ហារុំចិញ្ចៀន ស្មៀកសំពត់ខៀន ពាក់
អាវសាវថ្មី ស្មៀតសក់សសាល់ ក្តីញីសោភី សុភាពដូចស្រី ទេព

អប្សរសួគ៌ ៗ រើសរកកូនប្រុស ឆោមឆាយស្រៀបស្រស់ ស័កសម
គាប់គួរ ពាក់ពារពស្ត្រា រៀបគ្នាជាជួរ កិលកែទទួល កាន់ពាន
ព្រះស្រី ៗ ខ្លះកាន់ព្រះពស្ត្រ ព្រះសុទ្ធរស់ព្រះវិជនី ព្រះខ័ត្គព្រះខាន់
សោភ័នព្រះស្រី ព្រះសុគន្ធពី - សេសសំអាងអង្គ ៗ កាន់ព្រះភូសា
កាន់ព្រះកនិច្ឆ រៀបរាយរៀងរង រាងរូបឧត្តម ស័ក្តិសមមានទ្រង់
ដំរើធំទង់ ធំភាសហាត្ថា ៗ ក៏កាន់គ្រប់គ្រឿង ល្អល្អះរុងរឿង ដើរ
ដូចតារា ត្រចង់ត្រចះ ហែព្រះចន្ទ្រា ប្រទក្សិណមហា - សុមេរុបពិត ៗ
ព្រះពោធិ - ផ្កាស័ក្តិឧត្តុង្គ ឧត្តមប្រាកដ ប្រកបទ្រង់នូវ ព្រះភូសាសុទ្ធ
មាសមានមរកដ កែមកែវសុវណ្ណា ៗ ព្រះហស្តទ្រង់ព្រះ ទម្រង់ត្រចះ
ត្រចង់ថ្លៃថ្លា សឹងសូរ្យកានពេជ្រ រត្នរេបរេខា ទ្រង់ព្រះពស្ត្រា រឿង
រត្នកម្ពល ៗ ក្សត្រីវរវង្ស រវាសទ្រទ្រង់ គ្រប់គ្រឿងមង្គល មរកដ
រត្នកៅ កែវការកណ្ដាល កនូតសួស្តិ៍សល់ ស័ក្តិសមអង្គអគ្គ ៗ ខាង
ទ្រង់ព្រះពស្ត្រ ប្រពៃស្រៀបស្រស់ ភូសាប៉ុនប៉ាក់ សឹងសែសយ
មាស ពោរពាសដេរដាក់ ទ្រង់ព្រះសូភក្ត្រ សោភាវៃងរាស ៗ
ទ្រង់ព្រះទម្រង់ តម្រួតក្បាច់ហា - ផ្កាសមសោភាស លួសលាយ
ទងទាក់ ដាំដាក់ពេជ្រពាស រុងរឿងចុះឆ្លាស់ កាលកែវសូរ្យកាន ៗ

(មានត)

# ពង្ហអក ស៊ីទ្ធិប

ហ្វូងទិពន្ធមន្ត្រី ញ៉ុក - ថែម រៀបរៀង

(តទក)

នៅទីនោះ មាននាងកញ្ញាជាតិតណ្ហៀតនោកទទ្រាលកសិបដូចផ្កាលិសជុ (Lys d'eau) នៅអមសង់ទាង នាងគន្ធា និងនាងគោត្តមី មានសភាពដូចផ្កាក្រពុំនៃបទុមគ្រោះ ស្រស់ញញឹមក្នុងចំណោមនារី ដ៏ត្រកាលដូចស្លឹកឈើធ្វើពីសរសៃស្ប្រិត ហើយទ្រង់លាន់ព្រះឱស្ឋថា "ឱនារីសំឡាញ់របស់ជេដ្ឋា នាងកល់គ្នាគួរឲ្យចាប់ចិត្តស្នេហាណាស់ ធ្វើឲ្យជេដ្ឋាពិបាកនឹងចាកចោលនាងទៅ ប៉ុន្តែបើជេដ្ឋាមិនចាកចោលទៅទេ, យើងកល់គ្នាមុខជាត្រូវឯកមរណៈគ្រប់សព្វគ្រប់រូប ។ នាងកល់គ្នាដេកលក់ដូច្នេះ មុខជានឹងស្លាប់ដូចគ្នាទាំងអស់ ហើយបើកាលណា ផ្កាកុលាបរុះពេយទៅ គេក៏ពុំនក្រអូបនឹងលំអងផ្កាទៅឯណាទៅ? កាលបើចង្កៀងអស់ប្រេងហើយរលត់ទៅ គេគណ្ដាតភ្លើងអណ្ដាតបាត់ទៅណា? ឱ ពត្រី! អ្នកធ្វើឲ្យត្របកភ្នែកនាងទាំងនោះធ្ងន់ចុះទៅ ហើយបិទបបូរមាត់ជិត ដើម្បីកុំឲ្យមានទឹកភ្នែក ឬ ស្ករសំលេងអ៊ូកើតឡើង ដែលជាទំនាស់ដល់ដំណើររបស់ខ្ញុំ ។ ដោយសារនាងកុមារីអស់នេះហើយ ដែលបានធ្វើជីវិតខ្ញុំឲ្យសប្បាយរីកពេយ ប៉ុន្តែបែរជាថប់ព្រួយទៅវិញ ព្រោះនាងកល់គ្នាក៏ ខ្ញុំក៏ សត្វលោកទូទៅក៏ សុទ្ធរស់នៅដូចដើមឈើ ជាឈើ

ដែលកើតឡើងក្នុងសិសិររដូវ ត្រូវទទួលទ្រាំទ្រនូវទឹកភ្លៀង; គ្រាប់ព្រិល និងរដូវរងា ហើយក៏មានស្លឹកលឿងទុំស្លាប់ទៅ ហើយក៏កើតឡើងវិញទៀត ក្នុងសិសិររដូវក៏មាន ឬចួនកាលត្រូវកាប់បំផ្លាញដោយប៉ូវថៅក៏មាន ៗ ខ្ញុំមិនត្រូវការឲ្យមានសភាពបែបនេះទេ ឯខ្លួនខ្ញុំមានជីវិតនៅក្នុងលោកនេះ ដូចជាព្រះ ខ្ញុំមិនត្រូវការដូច្នេះទេ គឺបើខ្ញុំសុខស្រួលពេញលេញតែម្នាក់ឯង តែចំណែកមនុស្សជាតទូទៅខ្សឹកខ្សួលក្នុងទីអន្ធការ ៗ ហេតុដូច្នេះ នែនាងសំឡាញ់របស់ផ្កា ៗ សូមលាចាកទៅ! នោះបើជីវិតផ្កាសមគួរនឹងលះបង់ឲ្យ ក៏លះបង់ឲ្យបាន ហើយព្រះឆន្ទា នឹងត្រេចទៅរកវិមុត្តិ ដែលរួចផុតចាកក្នុងទុក្ខទាំងពួង និងពន្លឺដែលមិនទាន់មានគេដឹងស្គាល់ ៗ

រូបព្រះអង្គទ្រង់យាងសន្សឹមៗ ទៅកណ្តាលហ្វូងនាងកញ្ញាដែលកំពុងដេកលក់ ព្រះសិទ្ធត្ថៈ ទ្រង់ស្តេចយាងចេញទៅក្នុងពេលរាត្រីក្នុងយប់នោះ ហាក់ដូចដួងតារាទាំងឡាយមានភ្នែកក្រឡេកមើលព្រះអង្គដោយសេចក្តីស្នេហា ព្រះពាយផាត់ព្រះកូសាកាសាវរែករំភើយ ៗ បុប្ផាក្នុងសួនច្បារ មានស្រទាប់ក្តោបដិត ឥឡូវបែរជាបើកស្រទាប់រីករាយផ្សាយគន្ធពិដោរឈ្ងុយឈ្ងប់ មានលំអងផ្ការអណ្តែតរេយរាយទៅនៅទីពាល់ស្រពិចហិមាលយ៉ាដល់សមុទ្រតណ្ហា សឹងញាប់ញ័ររំជួយហាក់ដូចព្រលឹងនៃនាងធរណី រំភើបរំជួលដោយមានសន្សឹមយ៉ាងចំឡែក

ច្បាប់មិនត្រូវ ហើយព្រះគម្ពីរដែលដំណាលអំពីប្រវត្តិនៃព្រះជាអម្ចាស់
យើង ក៏បន្លឺសូរស័ព្ទពិរោះល្វេងល្វើយ ហាក់ដូចតន្ត្រីទិព្វដែលពួក
ទេវតាលេងកំសាន្ត ទាំងទិសខាងកើតទាំងទិសខាងលិច ធ្វើឲ្យរាត្រី
ក្សាន្តប្រកបដោយបីតិរីករាយទៅ ទាំងទិសខាងជើងទាំងទិសខាង
ត្បូង ។ មិនប៉ុន្មែប៉ុណ្ណោះ ស្ដេចចតុលោកបាល ទាំង ៤ អង្គចុះមកកាន់
ប្រឹថពីជិតក្លោងទ្វារមហាប្រាសាទ យាងចូលទៅម្ដង ១ គឺ ជាមួយនឹង
ពួកទេវតាមានស្មើគ្រឹផ្ទែក តែមើលមិនឃើញរូប កាន់ការុជដាំត្បូង
ពេជ្រ ប្រាក់, មាស, នឹងត្បូងមុក្តា ប្រណម្យហត្ថផ្គងអញ្ជលីតាមហែ
ហមក្សត្រឥណ្ឌ ] ដែលមានព្រះនេត្រដោកដោយអស្សុធារាទ្រង់ទតទៅ
ផ្កាយទាំងឡាយ ទ្រង់បិទព្រះឱស្ឋជិត ទ្រង់រំពឹងពិចារណាយ៉ាង
ជ្រាលជ្រៅ នូវគ្រោងការប្រកបដោយសេចក្តីករុណាដ៏ជំទូលាយជ្រាល
ជ្រៅ ៗ រួចព្រះអង្គស្ដេចយាងចូលទៅក្នុងទីងងឹត ហើយមានព្រះ
ឱង្ការថា "នាយឆន្ន: ក្រោកឡើងនាំយកសេះកណ្ឋកៈចេញមក" ។

នាយសារថីក៏បានក្រោកឡើងពីដំណេក ដែលខ្លួនបានដេកជិត
ក្លោងទ្វារ ក្រាបបង្គំទូលសួរថា "បពិត្រព្រះម្ចាស់ថ្លៃ ទ្រង់មានព្រះបំ
ណងដូចម្ដេច កាលបើផ្លូវគ្រប់ផ្លូវងងឹតឈឹងទាំងម៉្លេះ ទ្រង់បរពាជីទៅ
ទាំងរាត្រី ? -

ព្រះសិទ្ធាថ៌ៈ ត្រាស់ថា "និយាយតិច ៗ នាំសេះមកឲ្យខ្ញុំឆាប់ ៗ ដ្បិតពេលម៉ោងដល់ហើយ ខ្ញុំត្រូវចេញចាកគុកមាសត្បូវនេះឯង ដើម្បីដកខ្លួនចេញចាកទ្រុងទៅស្វែងរកសេចក្ដីពិត តាំងពីឥឡូវនេះទៅ ដរាបទាល់តែខ្ញុំបានជួបប្រទះនឹងសេចក្ដីពិតនោះ ដើម្បីជួយស្រោចស្រង់មនុស្សជាតិទាំងឡាយ" ។

នាយសារថីក្រាបបង្គំទូលតបថា "បពិត្រក្សត្រថ្លៃប្រសើរអើយ, ពួកមុនីនឹងតស់បានសង្កេតពិនិត្យមើលផ្កាយ បានទាយទុកថា ព្រះរាជបុត្របង្កើតនៃព្រះបាទសុទ្ធោទនៈ នឹងបានគ្រប់គ្រងត្រួតត្រាអាណាចក្រជាច្រើន ហើយបានសោយរាជ្យជាស្ដេចចក្រពត្តិរាជ? — តើព្រះអង្គស្ដេចចង់យាងចេញទៅ បោះបង់ចោលនូវលោក នូវរាជសម្បត្តិដែលជាកម្មសិទ្ធិរបស់ព្រះអង្គ ហើយទ្រង់សព្វព្រះទ័យកាន់ចានដើរសុំទានគេដូច្នោះឬ? — តើព្រះអង្គចង់ស្ដេចទៅកាន់ពលខ្សាចដ៏រហោឋាននៅទីប្រកបដោយសេចក្ដីក្រៀមក្រាន្តសប្បាយ គេទុកដូចជាឋានសួគ៌របស់មនុស្សលោក ព្រះអង្គមិនសព្វព្រះរាជហឫទ័យទេឬ ?—

ព្រះបរមក្សត្រទ្រង់មានព្រះបន្ទូលតបថា "នោះហើយដែលខ្ញុំត្រូវការ មិនមែនរាជបល្ល័ង្កទេ ឯរាជសម្បត្តិដែលខ្ញុំប្រាថ្នា ប្រសើរថ្លៃថ្លាជាងរាជអាណាចក្រទាំងអស់ ប្រសើរជាងរបស់ទាំងអស់ ដែលមានសេចក្ដីប្រែប្រួលនឹងសេចក្ដីស្លាប់ជាធម្មតា; ឆាប់ឡើងនាំសេះកណ្ឋកៈមកឲ្យខ្ញុំ"

នាយសារថីក្រាបទូលឡើងទៀតថា "បពិត្រព្រះម្ចាស់ថ្លៃជាទីគោរព, សូមព្រះអង្គទ្រង់នឹករំពឹងដល់សេចក្ដីទុក្ខព្រួយនៃព្រះបរមរាជបិតា, សូមទ្រង់រឭកនឹកដល់សេចក្ដីទុក្ខសោកឥតល្ហែនៃព្រះរាជទេពី ដែលមានតែព្រះអង្គមួយដែលនាំឲ្យព្រះនាងសុខសប្បាយ? តើព្រះអង្គនឹងជួយសង្គ្រោះដូចម្ដេច កាលបើព្រះអង្គបោះបង់ចោលទៅ?

ព្រះសិទ្ធាថ៌ទ្រង់តបថា "សម្មាញ់. សេចក្ដីស្រឡាញ់ចំពោះវត្ថុដែលគួរស្រឡាញ់ ដើម្បីនាំមកនូវសេចក្ដីសុខសប្បាយចំពោះខ្លួនឯង មិនមែនជាសេចក្ដីស្នេហាត្រឹមត្រូវទេ ឯខ្លួនខ្ញុំនេះ ខ្ញុំស្រឡាញ់ព្រះវរបិតានឹងមហេសីក្រៃលែង ជាងសេចក្ដីសុខសម្រាន្តផ្ទាល់ខ្លួនទៅទៀត ក្រៃលែងជាងសេចក្ដីសុខរបស់ជនទាំងពីរ ទើបខ្ញុំត្រូវចេញទៅ ដើម្បីជួយស្រោចស្រង់ជនទាំងពីរនឹងសត្វលោកទាំងឡាយ ខ្ញុំនឹងញុំាងសេចក្ដីមេត្តាឲ្យមានកំឡាំងខ្លាំងក្លាឡើង ដើម្បីញុំាងផលដែលខ្ញុំបំណងឲ្យបានសម្រេចទៅ, នាំសេះកណ្ឋកៈមកឲ្យខ្ញុំ" –

គ្រានោះ នាយឆន្ន ក្រាបទូលថា "បពិត្រព្រះម្ចាស់ថ្លៃ ទូលព្រះបង្គំទទួលព្រះឱង្ការឡូវហើយ" ហើយនាយឆន្នក៏ដើរទៅកាន់រោងពាជីដោយចិត្តព្រួយបារម្ភ ទឹកមុខក្រៀម, កាន់យកបង្ហៀរប្រាក់ ខ្សែបង្ហៀរ ខ្សែទ្រូង និងគ្រឿងប្រដាប់ដទៃទៀត បន្ទំបង្ហៀរ ចងសក់សេះហើយក៏ដឹកសេះកណ្ឋកៈចេញទៅ រួចចងកងសិតសក់ ចងអាន

សព្វគ្រប់ហើយក៏អង្អែលខ្លួនសេះ ដែលមានរោមសដូចហិមៈ ក្តីថាដូចសារ-សៃស្ត្រ; រួចគេយកក្រមាលទុមជៈសណ្ឋានបួនជ្រុងចតុរស្សក្រាលពីលើកែបសេះរួចគេដាក់កែបដ៏វិចិត្រ ចងរឹតដោយខ្សែដាំត្បូងពេជ្រផ្សេង ៗ ដាក់ខ្សែហាងនិងខ្សែខ្នង និងឈ្នាន់តាំងសងខាងសឹងមាសបម្លាក់ នៅទីបំផុត គេប្រដាប់ដោយខ្សែសយស្ត្រភ្លឺផ្លេកដូចមាស ដាំត្បូងមុក្តាគ្រាប់ធំ ៗ ហើយគេដឹកអាជានេយ្យ មកកាន់ក្លោងទ្វារព្រះរាជវាំងដែលព្រះអង្គគង់រង់ចាំ អាជានេយ្យមានចិត្តរីករាយសប្បាយកាលបានឃើញព្រះអង្គជាម្ចាស់ក៏ហើយក៏ស្រែកសំដែងអំណរ ប្រមុះក៏ក្រហមព្រាលសមដូចព្រះគម្ពីរសំដែងទុកថា "ជាការពិតណាស់ អ្នកផងគង់នឹងបានឮស្នូរសម្រែកនៃសេះកណ្ឋកៈ និងស្នូរស្បែកជើងដែកដែលរាតទ្រូដីៈ ប្រសិនបើពួកទេវតា មិនបានបិទបាំងត្រចៀកពួកអ្នកដេកលក់ទាំងអម្បាលមាណមិនឲ្យឮស្នូរស័ព្ទអស់នោះ" ។

ព្រះសិទ្ធាថ៌ទ្រង់យកព្រះហស្តអង្អែលក្បាលសេះទ្រង់ឱបករ ហើយមានព្រះបន្ទូលថា "ម្នាលសេះកណ្ឋៈ ចូលឯងនៅឲ្យស្ងៀម ហើយត្រូវនាំអញធ្វើដំណើរចេញទៅកាន់ផ្លូវឆ្ងាយ ដែលមិនធ្លាប់មានអ្នកជិះសេះណាមួយបានធ្វើមកពីមុនឡើយ ពីព្រោះយប់នេះអញត្រូវចេញទៅស្វែងរកការពិត ហើយមិនដឹងជាចុងផ្លូវទៅចប់ត្រឹមណាទេ ប៉ុន្តែនឹងមិនចប់មុនស្វែងរកធម៌ឃើញនោះឡើយ ។ ដូច្នេះ នែអាជានេយ្យ ចូរឯងធ្វើចិត្តឲ្យក្លាហាន អង់អាចហើយឯងកុំទុចឲ្យសោះ បើទុកជាមានដាវទាំង

ពាន់មកពាំងកផ្លូវក្ដី បើទុកជាមានកំពែងថ្មស្នាមក្រោះមកពាំងដំណើររបស់យើងក្ដី ។ នែឯងស្ដាប់ណា៎ះ! បើអញប៉ះផ្អឹងជំនីរឯងនែស្រែកប្រាប់ថា « ទៅ, កណ្ឋកៈ » ចូរឯងផាយយ៉ាងលឿនដូចខ្យល់ព្យុះដូចភ្លើងនឹងអា-កាស ដើម្បីធ្វើការជួយបោះហ្វាយផង ដូច្នេះ ឯងត្រូវមានចំណែកជួយឲ្យបានសម្រេចនូវឧត្តមគតិនេះ ដែលជួយស្រោចស្រង់ពិភពលោក ពីព្រោះអញចេញទៅគ្រានេះ មិនមែនគ្រាន់តែជួយសង្គ្រោះមនុស្សទេ គឺជួយសង្គ្រោះដល់សព្វសត្វទាំងអស់ ដែលបានទុក្ខលំបាក ហើយគ្មានសង្ឃឹមគ្មានសញ្ញាទីងទាមទារអ្វី ។ ដូច្នេះ ចូរឯងបញ្ចុះអញនាំទៅឥឡូវភ្លាមកុំបង្អង់ឡើយ » ។

រួចព្រះអង្គឡើងគង់លើសេះ ចាប់អង្អែលសក់ក្បាលពីខាងមុខ ហើយកណ្ឋកៈ ក៏ផាយចេញទៅលាន់ឮស្នូរសព្ទស្បែកជើងដែក នឹងស្នូរបង្ហៀរកង់រំពង ប៉ុន្តែឥតមាននរណាមួយបានឮស្នូរសំឡេងនេះទេ ពីព្រោះពួកទេព្ដាជាន់សុទ្ធាកាស ដែលមកហែហមព្រះអង្គ បានបេះផ្កាមោគ្រៈ ក្រហមឆ្អៅ ប៉ាចសាចតាមផ្លូវដែលទ្រង់ធ្វើព្រះដំណើរយ៉ាងក្រាស់ ហើយមានដៃទិព្វទាំទ្របង្ហៀរនឹងខ្សែមិនឲ្យឮស្នូរសព្ទអ្វី ។ មានគម្ពីរបាលីសេចក្ដីទុកថា « កាលដែលព្រះអង្គនឹងសេះកណ្ឋកៈស្ដេចទៅដល់ក្លោងទ្វារជាន់ខាងក្នុង មានពួកយក្ខបានយកសំពត់ដ៏វិចិត្រទ្រជើងសេះគ្រប់ដំហានជើងមិនឲ្យឮស្នូរសព្ទអ្វីឡើយ —

ប៉ុន្តែ កាលព្រះអង្គស្តេចទៅដល់ទ្វារលេងហ៊ិនប៉ាន់នោះលុះតែចំនួនមនុស្ស ១០០ នាក់ ទើបអាចបើកបានដោយលំបាកពន់ពេក តែទ្វារនោះបើកឯងយ៉ាងស្ងប់ស្ងាត់ តាមធម្មតានៅពេលបើកទ្វារម្តងៗ គេបានឮស្សូរសព្ទចំងាយពីរកោសៈ គគ្រែងគគ្រាំ ដូចស្សូរផ្គរលាន់ ស្សូរគងជ័ធំសំបើម ។

នាកាលព្រះសិទ្ធាថិស្តេចយាងទៅជិតដល់ទ្វារធំនៅចំកណ្តាលទីង-ទ្វារបន្ទាប់ទៀត សឹងរបើកឡើងឯងយ៉ាងស្ងប់ស្ងាត់ ក្នុងខណៈដែលទ្រង់ធ្វើព្រះដំណើរចេញចូលតាមទ្វារទាំងនោះ ; ពួកទាហានយាម ទាំងនាយទាហាន ទាំងកូនទាហាន សឹងធ្លាក់ដាវ លំពែងខែលពីដៃ ហើយដេកលក់ឥតដឹងខ្លួនដូចជាស្លាប់ - ពីព្រោះក្នុងពេលនោះ មានក-យោបក់រំភើយៗ ចេញមកពីវាលមល្វា (Molwa[១]) ដែលដាំដើមអាភៀនជាច្រើនហាក់ដូចសណ្តំអវយវៈ ឲ្យលង់លក់អស់ទៅដូច្នេះហើយបានជា-ស្តេចយាងចេញទៅបានដោយសេរី –

លុះដល់ថ្ងៃព្រឹករះឡើងពីជើងមេឃទិសខាងកើត ហើយមាន-ខ្យល់ព្រឹកព្រហាមបក់រំភើយឲ្យត្រជាក់លើក្រឡាប្រថពី ធ្វើឲ្យកើតជារលកនៅស្ទឹងអនោមា ដែលជាព្រំប្រទល់ដែនរៃព្រះរាជអាណាចក្រព្រះបរមក្សត្រក៏ទ្រង់បញ្ឈប់ពាជីនៅទីនោះ ទ្រង់ចុះមកផែនដី ហើយ

១ – ជាឈ្មោះខេត្ត១របស់ឥណ្ឌា ដែលគេដាំដើម Pavot សម្រាប់ធ្វើអាភៀនជាច្រើន ។

ទ្រង់ថ្នមអង្អែលសេះកណ្ឋកៈ ដោយព្រះទ័យមេត្តាប្រណី រួចទ្រង់មានព្រះ បន្ទូលទៅកាន់នាយឆន្នៈថា " អំពើដែលឯងបានធ្វើមកនេះ នឹងនាំ-ឲ្យឯងបានទទួលសេចក្ដីសុខ ចំពោះខ្លួនឯង ចំពោះសត្វលោកទាំងពួងផង, ចូរឯងជឿជាក់ថា អញស្រឡាញ់ឯងដោយស្មោះត្រង់ជានិច្ចដូច-ជាឯងបានសំដែងចិត្តស្មោះត្រង់ចំពោះអញ ។ ចូរឯងនាំយកសេះទៅ-វិញ ហើយយកព្រះមាលាដំរត្បូងមុក្តា ព្រះភូសាសម្រាប់ក្សត្រ ដ្បិតតាំងពីថ្ងៃនេះទៅ ទៅជារបស់ឥតប្រយោជន៍សម្រាប់អញ, ចូរយកព្រះកាយ-ពន្ធន៍ដាំពេជ្រ ព្រះខ័ននឹងព្រះកេសាវែង ដែលអញកាត់ចេញពីសិរសា ដោយព្រះខ័នបួរ ។ ចូរថ្វាយវត្ថុទាំងអស់នេះដល់មហាក្សត្រ ហើយក្រាបបង្គំទូលឲ្យទ្រង់ជ្រាបថា " សិទ្ធាថ៌សូមឲ្យទ្រង់ភ្លេចទំរាំតែទ្រង់ត្រឡប់ចូលមកវិញ ប្រកបដោយកិត្តិយសដ៏ខ្ពង់ខ្ពស់ជាង ១០ ដង នៃ-កិត្តិយសរបស់ក្សត្រ ដោយទ្រង់ស្វះស្វែងរកធម៌ឃើញតែមួយព្រះអង្គ-ឯង ។ កាលបើបានរកធម៌ឃើញហើយប្រែថាទាំងមូល ជារបស់អញ ហើយដោយការបំពេញពុទ្ធការកធម៌ ដោយសេចក្ដីមេត្តា! ពីព្រោះមនុស្សមានសង្ឃឹមតែក្នុងពួកមនុស្សផងគ្នា ហើយគ្មានជនណាមួយបានស្វះស្វែងរក ដូចអញមានបំណងនឹងធ្វើនេះទេ, ខ្លួនអញដែលលះបង់ពិភពលោកដើម្បីជួយស្រោចស្រង់ពិភពលោកទេតើ " ។

(មាន៨)

## និរយគាថា

(ចាកតេមិយជាតក)

មហាឧម - ណា គ្រីវ ប្រែ - រៀបរៀង

(តមក - ចប់)

---

រហទោ អយំ លោហកុម្ភិតបុព្វប្បុរោ

ទុគ្គន្ធរូបោ អសុចិ បូតិ វាយតិ

យស្មាភិតត្តា មនុជា បតន្តិ ។

ប្រែថា នរកនេះពេញទៅដោយឈាមនិងខ្ទុះ ជារបស់ស្មោកគ្រោក គួរខ្ពើម ពួកសត្វក្នុងនរកនេះ រមែងផឹកស៊ីឈាមនិងខ្ទុះដូសគាំងបាយទឹក ព្រោះអត់ទ្រាំសេចក្តីស្រេកឃ្លានមិនបាន ។

កម្មដែលឲ្យធ្លាក់នរកនេះ បានដល់ការសម្លាប់មាតាបិតានិងព្រះអរហន្ត មានគាថាជាតឹកតាងថា:

យេ មាតរំ បិតរំ វា ជីវលោកេ

ឃាតយិកា អរហន្តេ ហនន្តិ

តេ លុទ្ទកម្មា បសវេត្វា បាបំ

តេមេ ជនា លោហិតបុព្វភក្ខា ។

ប្រែថា ជនពួកណាក្នុងជីវលោកនេះ ជាអ្នកសំឡាប់មាតាបិតាឬ

ជាអ្នកសំឡាប់ព្រះអរហន្ត ជនពួកនោះ ចាត់ជាមនុស្សអាក្រក់អាក្រី គ្រាធ្វើសេចក្ដីអាក្រក់ហើយ រមែងមានឈាមទឹកខ្ទុះជាអាហារ ៗ

ក្នុងអដ្ឋកថាពន្យល់សេចក្ដីថា មិនមែនត្រឹមតែសំឡាប់ព្រះអរហន្ត ប៉ុណ្ណោះទេ សំឡាប់ភិក្ខុសង្ឃសាវកដទៃៗ ក៏ត្រូវធ្លាក់ក្នុងនរកនេះដែរ ៗ

១២ - **ក្ជតាវ៉ែនរក** នរកមនុស្សកោងក្នុងនរកនេះមានពួកនាយនិរយបាល យកសន្ទូចដែកធំៗ ប៉ុនដើមត្នោត ការថ្ពក់អណ្ដាត របស់សត្វនរក ទឹងបោះភ្ជាប់ដៃជើងសត្វនរក សន្ទឹងត្រដាងទុកទឹងដែនដែកក្រហម ដូចគេបោះសន្ទឹងស្បែកភ្ជាប់ទុកលើដែនដី មានគាថានិពន្ធទុកមកថា

ជីវពាហុ បស្ស ពលិសេន វិទ្ធំ
វិហាតំ យថា សង្កុសតេន ចម្មំ
ជន្តិ មញ្ញារ ជលម្ហិ ទិត្តា
ឧញ្ចន្តិ ខេទន្សំ រុធមានា គាមេភេ ៗ

ប្រែថា ចូរមើលពួកសត្វនរក ដែលត្រូវការថ្ពក់អណ្ដាតទឹងសន្ទូច ត្រដាងសន្ទឹងទុកដូចត្រដាងស្បែក រមែងអន្ទះអន្ទែងដូចជាត្រីដែលគេចាប់បោះទៅលើគោក មានតែយំយោគហូរទឹកភ្នែកសស្រោកសស្រាក់ ៗ

កម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការដំឡើងថ្លៃទ្រព្យគោងរៀប ដោយឃើញដល់ការចំណេញ មានគាថាជាបទដ្ឋានថា

យេ កេចិ សណ្ឋានគតមនុស្សា
អគ្ឃេន អគ្ឃំ កយំ ហាបយន្តិ
កូដេន កូដំ ធនលោភហេតុ
ឆន្នំ យថា វារិចរំ វធាយ
ន ហិ កូដការិស្ស អត្ថិ តាណា
សកេហិ កម្មេហិ បុរក្ខិតស្ស
តេ លុទ្ធកម្មា បសវេត្វា បាបំ
តេមេ ជនា វដ្ឋយេស្ត សយន្តិ ។

ប្រែថា បុគ្គលណា បានទទួលដៃថ្លៃលក់របស់ ហើយដៃថ្លៃកោងរៀបវេរ ព្រោះឃើញដល់ទ្រព្យ បំណែកសំដីនិយាយទន់ភ្លន់ផ្អែមល្ហែមពីរោះ ដើម្បីបិទបាំងលាក់លៀមការកោងរៀបរបស់ខ្លួន ដូចមនុស្សដែលអែបលាក់ខ្លួនពួនបាញ់សត្វ អ្នកដែលកោងរៀបដូចនេះ រមែងមិនមានអ្វីការពារមិនឲ្យធ្លាក់នរកបាន កាលស្លាប់ហើយរមែងត្រូវសន្ធូបថ្កក់អណ្ដាតក្នុងនរកនេះ ។

១៣– អយបព្វតនរកៈ នរកភ្នំដែក ក្នុងនរកនេះពួកសត្វនរកត្រូវចាប់បោះទៅក្នុងទឹកទង់ដែងខ្លះ ត្រូវភ្នំសង្កត់សង្កិនខ្លះ មានគាថាថា គ្រៀងអានថា

ចារី ឥមា សម្បវិកិច្ចកត្តា
បគ្គយ្ហ ករុណំ កុជា រុជន្តា
សុមត្ថកា លោហិតបុព្វលិត្តា
គាវោ យថា អាឃាតនេ វិកន្តា
ឲ្យាតវត្តន្តិ សជោតិភូតា ។

ប្រែថា ស្រីពួកនេះ ត្រូវនាយនិរយបាលចាក់ពង់កាយសព្វសុះនាំគ្នាលើកដៃទ្រហោយំ មានពង់កាយប្រឡាក់ឡោះទៅដោយឈាមនឹងខ្ទុះ ពួកនាយនិរយបាលដេញឲ្យចុះទៅក្នុងផែនដែកក្រហមត្រីមបង្កើះ នឹងករមើកឆាកតទៅមកមិនបាន ដូចគោដែលគេឃុំឃាំងទុកក្នុងគោលសំរាប់សំឡាប់ ស្រីពួកនេះ មានពង់ធំធាត់ ឆេះជាអណ្តាតភ្លើង ។

ក្នុងអដ្ឋកថាថា ស្រីសត្វនរកពួកនេះ មានពង់កាយធំប៉ុនភ្នំ ក្នុងខណៈដែលនាយនិរយបាល ឃុំឃាំងទុកលើផែនដែកក្រហមលិចចុះទៅត្រីមបង្កើះនោះ មានភ្នំដែកដែលឆេះជាអណ្តាតភ្លើង រមៀលមកអំពីទិសទាំង ៤ សង្កត់សង្កិនកំទេចស្រីពួកនោះឲ្យល្អិតជាធូលីទៅ ។

កម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការប្រព្រឹត្តកន្លងចិត្តស្វាមី មានពាក្យបាលីបញ្ជាក់ថា

កោលិត្ថិយាយោ ឥធ ជីវលោកេ
អសុទ្ធកម្មា អយុត្តំ អចារុំ

តា ធុត្តរូបា បតី វិប្បហាយ
អញ្ញំ អកាសុំ រតិចិត្តភោគា
តា ជីវលោកស្មឹ រមាបយិត្វា
ចក្ខាតិវត្តន្តិ សងោតិកូតា ។

ប្រែថា ស្រីពួកណាក្នុងជីវលោកនេះ ជាអ្នកទុច្ចរិតប្រព្រឹត្តមិនសមគួរ គឺប្រព្រឹត្តផិតក្រៅចិត្តស្វាមី គប់រកបុរសដទៃ ព្រោះឃើញដល់សេចក្តីស្រើបស្រាលរីករាយ លុះស្រីពួកនោះស្លាប់ហើយរមែងធ្លាក់ក្នុងនរកនេះ មានកាយធំប៉ុនភ្នំ ត្រូវភ្លើងឆេះសន្ធោសន្ធៅនៅជានិច្ច ។

១៤ – **ជលិតអង្គារនរក** : នរករណ្តៅរងើកភ្លើង ក្នុងនរកនេះមានរណ្តៅធំ ១ ពេញទៅដោយរងើកភ្លើង ពួកនាយនិរយបាលដេញចាក់ពួកសត្វនរកទៅលើផែនដែកក្រហមទាំងហ្វូង ៗ ដូចហ្វូងគោក្របី លុះដេញទាន់ហើយ ក៏ចាប់ហោះបុះទៅក្នុងរណ្តៅរងើកភ្លើងដ៏ក្តៅនៅជានិច្ច មានគាថាភាសិតថា

ធាវន្ត ករោត្វា តិសវ្សមេ បនេតេ
អវំសិរា នរកា ចាតយន្តិ ។

ប្រែថា ពួកសត្វក្នុងនរកនេះ រមែងត្រូវនាយនិរយបាលចាប់យកជើងឡើងលើ យកក្បាលសំយុងចុះក្រោម ហោះបុះទៅក្នុងនរក ។

បាបកម្មដែលនាំឲ្យធ្លាក់ចុះ នរកនេះ បានដល់ការប្រព្រឹត្តិអនាចារនឹងកិរិយាអ្នកដទៃ មានគាថាសំអាងថា :

យេ ជីវលោកស្មឹ អសាធុកម្មិនោ
បរស្ស ទារានិ អតិក្កមន្តិ
តេ តាទិសា ឧត្តមភណ្ឌថេនា
តេមេ ជនា (អវំសិរា) នរកេ បាតយន្តិ
តេ វស្សបូគានិ ពហូនិ តត្ថ
និរយេសុ ទុក្ខំ វេទនំ វេទយន្តិ
ន ហិ បាបការស្ស ភវន្តិ តាណា
សកេហិ កម្មេហិ បុរក្ខតស្ស
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា (អវំសិរា) នរកេ បាតយន្តិ ៗ

ប្រែថា បុរសពួកណាក្នុងជីវលោកនេះ ជាអ្នកធ្វើកម្មមិនល្អគឺកន្លងប្រពន្ធនិងភរិយាអ្នកដទៃ បុរសពួកនោះ ត្រូវនាយនិរយបាលចាប់ក្បាលសំយុងចុះ ប្រោះចុះទៅក្នុងនរក បុរសពួកនោះរមែងទទួលទុក្ខវេទនានៅក្នុងនរកអស់កាលដ៏យូរយារ, បុរសដែលកសាងសន្សំធ្វើសេចក្តីអាក្រក់ទុកទាំងនោះ រមែងមិនមានអ្នកការពារ លុះគេស្លាប់ហើយ រមែងត្រូវនាយនិរយបាលចាប់សំយុងក្បាលចុះក្រោម ប្រោះចុះទៅក្នុងនរក ៗ

១៥ — មិច្ឆាទិដ្ឋិកនរកៈ នរកមិច្ឆាទិដ្ឋិ គឺពួកអ្នកដែលជាមិច្ឆាទិដ្ឋិ រមែងធ្លាក់នរកនេះ មានគាថាជាគ្រឿងសំអាងថា

ឧច្ចាវចាមេ វិធា ឧបក្កមា
និរយេសុ តិដ្ឋន្តិ សុឃោររូបា

ប្រែថា សត្វនរកពួកនេះ សុទ្ធតែជាអ្នកប្រកបដោយកម្ម មានរូបរាងគួរខ្លាច នៅក្នុងនរកនេះ ។

ក្នុងអដ្ឋកថាថា ពួកសត្វក្នុងនរកនេះ សុទ្ធតែជាអ្នកមានសេចក្ដីយល់ឃើញខុស គឺយល់ឃើញថា "ឲ្យទានមិនមានផល, ការបូជាធំមិនមានផល, ការបូជាតូចមិនមានផល, ការធ្វើល្អអាក្រក់មិនមានផល មាតាមិនមាន, បិតាមិនមាន, សមណព្រាហ្មណ៍មិនមាន, សត្វដែលជាឧបបាតិកមិនមាន, លោកនេះមិនមាន, លោកខាងមុខមិនមាន" មានគាថាបញ្ជាក់ថា

យេ ជីវលោកស្មឹ សុបាបទិដ្ឋិនោ
វិស្សាសកម្មានិ ករោន្តិ មោហា
បរញ្ច ទិដ្ឋីសុ សមាទបេន្តិ
តេ បាបទិដ្ឋី បសវេត្វ បាបំ
តេមេ ជនា អនិមត្តា ទុក្ខា តិប្ប
ខរា កដុកា វេទនា វេទយន្តិ ។

ប្រែថា បុគ្គលពួកណាក្នុងជីវលោកនេះ ជាអ្នកមានសេចក្ដីយល់ឃើញខុស ធ្វើបាបកម្មផ្សេងៗដោយខ្លួនឯងខ្លះ ដឹកនាំឲ្យបុគ្គលដទៃយល់

ឃើញទុសតាមខ្លួនខ្ទះ បុគ្គលពួកនោះលុះស្លាប់ហើយ រមែងបានទទួលសេចក្តីទុក្ខយ៉ាងធំ មានទុក្ខៈវេទនាដ៏ក្តៅខ្លោចផ្សាយ៉ាងពន់ពេកណាស់ ។

## និគមភាសិត

ទី ១ វេតរណីនទី ទី ២ សុនខនរកា
ទី ៣ អយបវរណា ៤ អង្គារកាសុនរក ។
៥ នរកលោហកុម្ភី ទី ៦ អយោទកៈ
ទី ៧ នរកថុសៈ ៨ អយសូលៈណា ។
៩ សញ្ជោតិនរក ទី ១០ គូថៈនរកា
១១ លោហិតបុព្វកគ្គា ១២ ឈ្មោះកូដការី ។
១៣ អយបព្វតៈ ១៤ផលិតអង្គារនរក
១៥ តិម្ពុជាវិដ្ដក៍ រួមន័យជា ១៥ រណ្តៅ ។

នរកទាំងនេះឥតសុខសាន្ត សុទ្ធសឹងរំខានបានសោកសៅ
សែនទុក្ខបុកម្នេញពេញក្តួលក្តៅ សមតាមកម្មខ្មៅដែលខ្លួនសាង ។
គួរកោតគួរខ្លាចគួរកុំធ្វើ អំពើអាក្រក់គ្រប់បែបយ៉ាង
អកុសលកម្មគ្មានផ្លូវគាង មុខជាជួលធ្លាងទៅអបាយ ។
បើមិនតិរច្ឆានក៏គង់ប្រេត បើមិនប្រេតគង់អសុរកាយ
ឬធ្លាក់នរកផងទាំងឡាយ ក្រហល់ក្រហាយឥតសាន្តសុខ ។
ណាគ្រីបណ្ឌិតប្រឹតប្រឹងប្រែង ប្រែតែងរៀបរៀងរឿងនរក
ចាកនេមិរាជជាតក សាធកសង្ខេបប៉ុណ្ណោះហោង ។

# អំពីតាំងចៅអធិការថ្មី

(តមក)

---

សញ្ញាប័ត្រលេខ ៤៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ដួង-ចាប នាមឆាយា ចន្ទត្ថេរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តស្វាយចារ ឃុំស្តុក ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឆន-ភោគ នាមឆាយា កណ្ហត្ថេរ កើតឆ្នាំថោះ អាយុ ៣៥ វស្សា ១៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លឹម-ញ៉េន នាមឆាយា ញាណប្បញ្ញោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តទឹកជ្រៃ ឃុំទឹកល្អក់ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-សួន នាមឆាយា សុវណ្ណប្បញ្ញោ កើតឆ្នាំខាល អាយុ ២៣ វស្សា ២ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខឹម-ជិន នាមឆាយា ពុទ្ធញាណ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាចៅអធិការ វត្តប្រេស ឃុំត្របែក ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤៦៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុម-យ៉េ នាមធាយា ធម្មប្បញ្ញា កើតឆ្នាំរកា អាយុ ៤១ វស្សា ២១ ជាចៅអធិការ វត្តសារិនឃ្លាន ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤៦៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-ណៃ នាមធាយា មុនីសុធម្ម កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១១ ជាចៅអធិការ វត្តមគាគីរី ឃុំត្រពាំង ស្រុកកំពង់សោម ខេត្តកំពត ។

សញ្ញាប័ត្រលេខ ៤៦៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ធើត នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំរកា អាយុ ២៩ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សួរ-យិម នាមធាយា គន្ធត្ថេរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តសាលាម្នាង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គួយ-ចិក នាមធាយា សុធម្មត្ថេរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៦៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហាស-យិម នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តគិរីអន្ទុំ ឃុំពោធិបឹង ស្រុកកំពង់សោម ខេត្តកំពត ។

សញ្ញាប័ត្រលេខ ៤៧០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ដួង-ធូរ នាមឆាយា គន្ធបញ្ញោ កើតឆ្នាំមមែ អាយុ ៣០ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ បួរ-ង៉ួន នាមឆាយា សុវណ្ណគោ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តអង្គគោក ឃុំដងតែង ស្រុកកំពង់សោម ខេត្តកំពត ។

សញ្ញាប័ត្រលេខ ៤៧២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខៀន-គី នាមឆាយា កិទីតត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តអទង់ឆ្អើត ឃុំដីខ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឡឹក-ទុយ នាមឆាយា ឥន្ទបញ្ញោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តពោធិ៍គិរី នៅឃុំចុស ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈិម-តាត់ នាមឆាយា ចន្ទបញ្ញោ កើតឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តគិរីសាគរ នៅឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចិក-ធន នាមឆាយា ញាណបញ្ញោ កើតឆ្នាំវក អាយុ ២៩ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តចំបក់មាស ឃុំសាន្ទែរ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៤៧៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាប់-ម៉ម នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំ ១៨៨៧ អាយុ ៦១ ជាចៅអធិការ វត្តសំពេង ឃុំចុងដូង ស្រុកញៀរវាញ់ ខេត្តឃ្លាំង (កូស័ងស៊ីន) ។

សញ្ញាប័ត្រលេខ ៤៧៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គិម-ក៉ា នាមធាយា វិនយបញ្ញោ កើតឆ្នាំ ១៩០៣ អាយុ ៤៥ វស្សា ២៤ ជាចៅអធិការ វត្តពោធិ៍ថ្កោក ឃុំកេកាង ទ័ណ្ឌឌិញបាញ់ ខេត្តឃ្លាំង (កូស័ងស៊ីន) ។

សញ្ញាប័ត្រលេខ ៤៧៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លិម-ស្ដើង នាមធាយា គិរីតន្ទកេសរ កើតឆ្នាំ ១៨៩០ អាយុ ៥៨ វស្សា ៣៧ ជាចៅអធិការ វត្តបួនព្រះកក្ត ឃុំកៀកគិម ទ័ណ្ឌញៀរវាញ់ ខេត្តឃ្លាំង (កូសាំងស៊ីន) ។

សញ្ញាប័ត្រលេខ ៤៧៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លិម-អិត នាមធាយា នពជោត កើតឆ្នាំ ១៨៨១ អាយុ ៦៧ វស្សា ៤៧ ជាចៅអធិការ វត្តចម្បា ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថាច់-ក៉ន នាមធាយា សមន្តសរ កើតឆ្នាំ ១៩១៥ អាយុ ៣៣ វស្សា ១៣ ជាចៅអធិការ វត្តខ្មែររង្សី ឃុំថាញ់ទ្រី ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សើន-សម នាមធាយា សទ្ធម្មប្បញ្ញា កើតឆ្នាំកុរ អាយុ ៤០ វស្សា ២៩ ជាចៅអធិការ វត្តបឹងក្របាប់ថ្មី ឃុំគងហីង ខ័ណ្ឌដេញមី ខេត្តឃ្លាំង (កូស័ងស៊ីន) ។

សញ្ញាប័ត្រលេខ ៤៨២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ាញ់-ហោ នាមធាយា សុវណ្ណជោត កើតឆ្នាំ ១៩១៧ អាយុ ៣១ វស្សា ៩ ជាចៅអធិការ វត្តកំពង់ទ្រេញ ឃុំធីងហ្វា ខ័ណ្ឌញៀវចាញ់ ខេត្តឃ្លាំង (កូស័ងស៊ីន) ។

សញ្ញាប័ត្រលេខ ៤៨៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ាញ់-ពំ នាមធាយា មុនីសុវណ្ណ កើតឆ្នាំ ១៨៩៥ អាយុ ៥៣ វស្សា ៣៣ ជាចៅអធិការ វត្តពាងសារ៉ែ ឃុំតាំងបិញ ខ័ណ្ឌ ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៤ ចុះថ្ងៃសុក្រ ២ កើតខែមិគសិរឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ទក-រ៉ន់ នាមធាយា សុវណ្ណតេរ កើតឆ្នាំឆ្លូវ អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តបទុមាតារ ឃុំអង្កពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤៨៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ខែម នាមធាយា ខន្តិវិជ្ជោ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ា-ថោង នាមឆាយា ឥន្ទត្តេរ កើតឆ្នាំរក អាយុ ៤១ វស្សា ១៦ ជាគ្រូសូត្រស្តាំ វត្តត្រពាំងវែង ឃុំព្រះនិព្វាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទុម-ណែម នាមឆាយា ធម្មជោត អាយុ ៣៨ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្តមង្គលមានជ័យ ឃុំភោធិ៍ម្រាល ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៨៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពៅ-ម៉ូវ នាមឆាយា ឥន្ទជោត កើតឆ្នាំមមី អាយុ ៤៣ វស្សា ២១ ជាចៅអធិការ វត្តគិរីវង្ស ឃុំកាំងខ្វាវ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៤៨៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន-គាំ នាមឆាយា សីលសុវណ្ណ កើតឆ្នាំរោង អាយុ ៥៥ វស្សា ១៧ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៩០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លិម-អ៊ាន នាមឆាយា វិនយត្តេរ កើតឆ្នាំ ១៩២២ អាយុ ២៦ វស្សា ៦ ជាចៅអធិការ វត្តរកាដួរ ឃុំឈើទាល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤៩១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គិម-ហ៊ុន នាមឆាយា ធម្មជោត កើតឆ្នាំច អាយុ ៣៩ វស្សា ១៨ ជាចៅអធិការ វត្តបឹងប្រា ឃុំឈើទាល ស្រុក-ខេត្តដដែល ។ (មានត)

កំណត់

# ស្នើអំពីរឿងស្ថាបនាវិទ្យាស្ថានមួយ

## សម្រាប់សិក្សាភាសាឥណ្ឌា-ខ្មែរ នៅភ្នំពេញ

**លោកភ័យ - ប៊ុក ក្រុមការក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែចេញពីបារាំងមកខ្មែរ**

ការសិក្សាភាសាឥណ្ឌាទូទៅ ជាកិច្ចមានប្រយោជន៍ និងសារៈសំខាន់ចំពោះប្រទេសកម្ពុជា ដូចគ្នានឹងការសិក្សាភាសាក្រិក - ឡាតាំង ដែលគេដាក់កល់ទុកសម្រាប់និស្សិតរៀនសូត្រ នៅសាលារៀនក្នុងប្រទេសបារាំង, ការចេះដឹងនូវភាសាសំស្ក្រឹតនិងបាលី ព្រមទាំងអារ្យធម៌ឥណ្ឌា ដែលទាក់ទងដោយអារ្យធម៌នៃប្រទេសជិតខាង ខាងផ្លូវប្រវត្តិសាស្ត្រ, ជាកិច្ចគួរបំពេញ ដើម្បីស្រាវជ្រាវនូវទំនៀមទម្លាប់ប្រពៃណីបុរាណខ្មែរ ដែលមានអត្ថដ៏គម្ភីរភាព ហើយនឹងងាយស្វែងរកនូវវត្ថុធាតុ ដែលជាបុព្វហេតុនៃទំនៀមទម្លាប់នោះ ។

ព្រោះហេតុដូច្នេះ ត្រូវតែបណ្ឌិតខ្មែរក្នុងកាលជាអនាគតប្រមូលគ្នាឲ្យបានច្រើនជាងមុន ដើម្បីនឹងចូលទៅសន្ទនាការអំពីរឿងបូព៌ាវិទ្យានិយមរវាងប្រជាជាតិ (l'orientatlisme international) មានការសិក្សាខាងភាសាឥណ្ឌាជាកិច្ចត្រូវស្វែងរកដោយពិសេស, បណ្ឌិតទាំងនោះ ក្នុងពេលសន្ទនាការរឿងរ៉ាវក្នុងសាកលលោក អាចឆ្លៀតឱកាសរកផល

ប្រយោជន៍ក្នុងរឿងនេះ ដាក់បញ្ចូលមកក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរបាន លោកអ្នកប្រាជ្ញទាំងប៉ុន្មាន អាចចូលទៅប្រស្រ័យចំពោះកិច្ចការខាងសាលាបាឡីនបូពាំប្រទេសដែលជាតំណាងក្នុងការស្វែងរកបូពាំវិទ្យានិយមជាសាធារណៈ អាចរៀបចំនូវក្រុមសញ្ញាតិខ្មែរ ខាងសិល្បាចារិកបុរាណវិទ្យា និងស្ថាបនានូវមជ្ឈមសិក្សានិស្សិតខ្មែរ ដែលត្រូវយកសាស្ត្រាចារ្យមានសមត្ថភាពខាងភាសាតំណៀមកបង្រៀនបានដោយឆាប់រហ័ស ។

ដើម្បីនឹងឧបត្ថម្ភបណ្ឌិតខ្មែរ ដែលពេញចិត្តក្នុងការស្វែងរករឿងនេះ, ប្រទេសបាពាំងសែសត្បូរស្នើចំពោះកម្ពុជរដ្ឋអំពីគ្រោងការស្ថាបនាវិជ្ជាស្ថាននៅក្រុងភ្នំពេញ សម្រាប់សិក្សាឧត្តមវិជ្ជា ដែលគេអាចយកគោលការសិក្សាកិច្ចស្វែងរកភាសាតំណៀនៃសាលាឧត្តមវិជ្ជានៅប៉ារីសមកបញ្ចូលផងបាន ។

ការសិក្សានេះ ត្រូវបើកសិទ្ធិឲ្យជនគ្រប់រូបចូលទៅរៀនបានដោយសេរី ឥតមានរើសមុខ, គុណបំណាច់ដែលរៀនក្នុងសាលានោះ ត្រូវបានសញ្ញាប័ត្រមួយដែលនឹងប្រគល់ឲ្យបាន លុះត្រាតែបេក្ខជននោះបានធ្វើកិច្ចការអ្វីមួយដ៏គាប់ប្រសើរ ហើយបានចូលទៅរៀនបណ្ដោះអាសន្ននៅសាលាក្នុងរយៈវេលា ២ ឆ្នាំ ដោយទទួលសេចក្ដីយល់ព្រមពី

គណៈកម្មការសាលា ដែលបានយករូបបេក្ខជនទៅបង្ហាញចំពោះចាងហ្វាងសាលានោះ ។

នៅភ្នំពេញ ការសិក្សានេះដែលនឹងធ្វើបាន លុះត្រាតែចាត់ចាងហ្វាងនៃការសិក្សាមួយនាក់ពីប៉ារីស ក្នុងរយៈវេលា ៦ ខែក្នុង ១ ឆ្នាំ, លេខាធិការដ្ឋានជាអចិន្ត្រៃនៃវិទ្យាស្ថានឧត្តមសិក្សានេះ ត្រូវមានសមាជិកខាងសាលាបូព៌ាប្រទេសម្នាក់មកកាន់ការនៅភ្នំពេញ បណ្ណាល័យនៃពុទ្ធ-សាសនបណ្ឌិត្យ សម្រាប់ជាមន្ទីរធ្វើការផ្សេងៗ នៃក្រុមនេះ, ប្រាក់ចំណាយក្នុងរឿងនេះ ត្រូវប្រទេសបារាំងសែស នឹងប្រទេសកម្ពុជាទទួលបន្ទុកជួយគ្នាទៅវិញទៅមក, ប្រាក់បៀវត្សនៃចាងហ្វាងសាលាត្រូវប្រទេសបារាំងសែសចេញឲ្យ បំណែកខាងប្រទេសកម្ពុជា ត្រូវចេញតែខាងប្រាក់ចំណាយសោហ៊ុយសំណាក់អាស្រ័យក្នុងទីនេះ នឹងថ្លៃយានជំនិះ ។

ចំពោះឆ្នាំ ១៩៥០ ប្រាក់ចំណាយក្នុងរឿងនេះ តាមសេចក្ដីស្មាននៃកដរដ្ឋាភិបាលខ្មែរប្រហែលជា ៦-៧ ម៉ឺនរៀល ។

---

# ១ – កែពាក្យខុស

នៅកម្ពុជសុរិយា ឆ្នាំ ១៩៤៩ លេខ ១០ ត្រង់សុភាសិតកាគទី ២ ទំព័រ ៧៣២

លេខ ៣៧

| ពាក្យជា: | កែជា: |
| --- | --- |
| ៣៧-បណ្ឌិតព្រឹទ្ធាចារ្យ បុរាណ បឋមកាល ប្អាត់ឈ្មោះចក្រពត្ត ឬមាននាមលុះសព្វថ្ងៃ ។ លោកជាស្រែវិទ្យា មានគុណថ្លៃ ក្បួនសាស្ត្រច្បាប់បវេណី ធម៌លោកតាមសម័យ មានគុណថ្លៃប្រសើរពិត ។ | ៣៧ – បណ្ឌិតព្រឹទ្ធាចារ្យ បុរាណបឋមកាល បាត់ឈ្មោះចក្រពត្ត ឬមាននាមលុះសព្វថ្ងៃ ។ លោកជាស្រែវិទ្យា ក្បួនសាស្ត្រច្បាប់បវេណី ធម៌លោកតាមសម័យ មានគុណថ្លៃប្រសើរពិត ។ |

លេខ ៤០

| | |
| --- | --- |
| ៤០ – មានហេតុមានផល សង្គ្រាមសាកល កើតទុក្ខទាន អគ្គីឆាបឆេះ សម្រាមប្រធាន ពាយោបក់ប្រាន ស្លឹកឈើរីក ៗ បាបបុណ្យគុណទោស កសាងតាមថ្នាក់ រូបល្អសមស័ក្តិ ដ្បិតកាន់សីលា ។ | ៤០ – មានហេតុមានផល សង្គ្រាមសាកល កើតទុក្ខទាន អគ្គីឆាបឆេះ សម្រាមប្រធាន ពាយោបក់ប្រាន ស្លឹកឈើរីក ៗ សត្វខុសបរិត មុខភាពផ្សេងចិត្ត ផលល្អលាមក បាបបុណ្យគុណទោស កសាងតាមថ្នាក់ រូបល្អសមស័ក្តិ ដ្បិតកាន់សីលា ។ |

# ៤ – សន្ទិកាប្រាប់ពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
| --- | --- | --- | --- |
| កំរិតប្រារព្ធ | កាំបិតប្រារព្ធ | ៧៣៣ | ៩ |
| គេស្គាល់ប្រាជ្ញាដោយការឆម្មតា | គេស្គាល់ប្រាជ្ញដោយការធម្មតា | ៧៣៤ | ១០ |